ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការទុកដាក់ស្រូវ




រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម



ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ** **មាស ពិសិដ្ឋ**
**និស្សិតបណ្ឌិតសិក្សា នៅសាកលវិទ្យាល័យម៉ាស្ស៊ី ប្រទេសញូវហ្សេឡែន**
**ទូរស័ព្ទៈ** **០១២ ៧៥៩៤៤០**
**អ៊ីម៉ែលៈ** pmeas@online.com.kh
pysethmeas@yahoo.com

**កាលបរិច្ឆេទ ខែ ធ្នូ ឆ្នាំ ២០០៥**

© រក្សាសិទ្ធិគ្រប់យ៉ាង គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍ អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹង ដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្រប តាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកសិត្រ-បរិស្ថាន ថ្នាក់ឃុំសង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋាន ជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន នានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករ ដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រទទួលឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

## អារម្ភកថា

ពាក្យពេញនៃ បអប គឺ “បទដ្ឋានអនុវត្តបច្ចេកវិទ្យា”។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ននានា ដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័ត និងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

# មាតិកា


១. ការពិពណ៌នា ..... ១

២. គោលការណ៍ណែនាំបច្ចេកទេស ..... ៣

២.១ មូលហេតុ ឬ ភាពចាំបាច់ក្នុងការបង្កើតឯកសារនេះ ..... ៣

២.២ ការបាត់បង់នៅក្នុងពេលទុកដាក់ ..... ៤

*២.២.១ ការបាត់បង់ជាបរិមាណ* ..... ៤

*២.២.២ ការបាត់បង់គុណភាព* ..... ៤

២.៣ ការគ្រប់គ្រងគ្រាប់ស្រូវនៅមុនពេលទុកដាក់ ..... ៥

*២.៣.១ ការប្រមូលផលក្នុងពេលវេលាត្រឹមត្រូវ* ..... ៥

*២.៣.២ ការបោកបែនជាបន្ទាន់ និង ពុំធ្វើអោយប៉ះទង្គិចខ្លាំង* ..... ៦

*២.៣.៣ ការសម្អាតសម្រស់* ..... ៨

*២.៣.៤ ការហាលសម្ងួត* ..... ៨

*២.៣.៥ កំណាជាញើស* ..... ៩

*២.៣.៦ កិច្ចការពារទល់នឹងសត្វកណ្ដុរ* ..... ១០

២.៤ ជម្រើស ឬ វិធីទុកដាក់បែបថ្មី ..... ១៣

*២.៤.១ ការទុកដាក់ជាគំនរ ឬ ដោយចាក់ចារ* ..... ១៣

*២.៤.២ ការទុកដាក់ក្នុងបាវ* ..... ១៨

*២.៤.៣ ការទុកដាក់ក្នុងបរិក្ខារបិទជិត* ..... ១៩

២.៥ ផលចំណេញអំពីការកែលម្អ ..... ២១

២.៦ ឥទ្ធិពលទៅលើបរិស្ថាន ..... ២៤

៣. គោលការណ៍ណែនាំក្នុងការផ្សព្វផ្សាយ ..... ២៤

៣.១ ផែនការការងារ ..... ២៤

*៣.១.១ ការកំណត់តម្លៃដែលត្រូវចំណាយ* ..... ២៤

*៣.១.២ អ្នកគាំទ្រ* ..... ២៥

*៣.១.៣ យេនឌ័រ* ..... ២៥

៣.២ វិធីសាស្ត្រផ្សព្វផ្សាយ ..... ២៥

*៣.២.១ ការជ្រើសរើសទីកន្លែង* ..... ២៥

*៣.២.២ ការជ្រើសរើសកសិករ និង ការរៀបចំ* ..... ២៦

*៣.២.៣ ការរួមចំណែកពីសំណាក់កសិករ និង អ្នកគ្រប់គ្រងការទុកដាក់ស្រូវ* ..... ២៦

៣.៣ ពិសោធន៍ និង ការអនុវត្តន៍បង្ហាញ ..... ២៦

*៣.៣.១ ចំណងជើង : ការទុកដាក់ស្រូវ* ..... ២៦

*៣.៣.៣ គោលបំណង* ..... ២៦

*៣.៣.៤ វិធីសាស្ត្រ* ..... ២៧

*៣.៣.៥ ការស្រង់ និង វិភាគទិន្នន័យ* ..... ២៧

## ១. ការពិពណ៌នា

### គោលបំណង និងសារៈប្រយោជន៍

ដោយយល់ឃើញថា

- ការកាត់បន្ថយនូវការបាត់បង់គ្រាប់ស្រូវនៅក្រោយពេលប្រមូលផលគឺជាមធ្យោបាយ ឬ វិធីដ៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយនូវទំហំដីស្រែចម្ការដែលត្រូវការសម្រាប់ការដាំដុះ និង ក្នុងការបង្កើននូវស្បៀងអាហារ
- ផលវិបាកនៃការទុកដាក់ផលិតផលនេះមិនសមស្របនៅកម្ពុជាមានសភាពធ្ងន់ធ្ងរ ហើយ
- ការផ្សព្វផ្សាយនូវចំណេះដឹងស្តីអំពីបរិក្ខារ និង បច្ចេកទេសទុកដាក់សមស្របដល់កសិករដែលមានស្រូវទុកនៅតែជាកិច្ចការយ៉ាងមានសារៈសំខាន់

ឯកសារនេះត្រូវបានរៀបចំឡើងដើម្បី

- ចងក្រងនូវព័ត៌មានដែលមានលក្ខណៈទាក់ទងនានាស្តីអំពីបច្ចេកទេស និង បែបបទទាំងឡាយដែលមានប្រសិទ្ធិភាព និង ងាយស្រួលអនុវត្ត ក្នុងការទុកដាក់គ្រាប់ស្រូវ ដោយផ្អែកទៅលើកិច្ចអនុវត្តន៍ជាក់ស្តែង និង លទ្ធផលនៃការស្រាវជ្រាវថ្មីៗ
- ផ្តល់ដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មនូវគោលការណ៍ណែនាំ និង ជម្រើសបច្ចេកទេសទាំងឡាយដែលមានលក្ខណៈមិនស្មុគ្រស្មាញ ងាយស្រួលអនុវត្តន៍ និង ជ្រើសរើស តម្រូវទៅតាមលក្ខខណ្ឌជាក់ស្តែង និង ធនធានដែលមាន ឬ អាចរកបានក្នុងការផ្ទេរនូវចំណេះដឹងដល់កសិករ និង អ្នកគ្រប់គ្រងស្រូវដើម្បីអោយគាត់អាចបង្កើនផលចំណេញ និង រក្សាបាននូវគុណភាពផលិតផល ។

### លក្ខណៈវិនិច្ឆ័យអំពីភាពសមស្របខាងផ្នែកបច្ចេកទេស

ដោយយកចិត្តទុកដាក់ទៅលើលក្ខណៈវិនិច្ឆ័យនានាដូចដែលមានរៀបរាប់ខាងក្រោម នឹងធ្វើអោយប្រាកដថាអនុសាសន៍នានាក្នុងឯកសារនេះអាចនឹងអនុវត្តបានសមស្របទៅតាមសេចក្តីប្រាថ្នា ។

### យេនឌ័រ

ការចូលរួមរបស់ស្ត្រីនៅក្នុងកិច្ចការនេះមានសារៈសំខាន់ជាទីបំផុត ។ ជាទូទៅស្ត្រីកម្ពុជាជាអ្នកធ្វើនូវកិច្ចការ ផ្ទះសម្បែងស្ទើរតែទាំងអស់ដោយរួមទាំងកិច្ចថែរក្សាកសិផលដែលប្រមូលបានដូចជាគ្រាប់ស្រូវជាដើម ។ ការ ផ្តល់ដល់ស្ត្រីនូវចំណេះដឹងស្តីពីបច្ចេកទេស និង វិធីទុកដាក់គ្រាប់ស្រូវ ព្រមទាំងកិច្ចការពារទប់ស្កាត់ចំពោះការបាត់បង់ដែលមានភាពសមស្របទៅតាមលក្ខណៈវិទ្យាសាស្ត្រ នឹងធ្វើអោយស្ត្រី និង ក្រុមគ្រួសារមានលទ្ធភាពយ៉ាងប្រាកដក្នុងការធ្វើអោយកាន់តែប្រសើរនូវសុវត្ថិភាពស្បៀង តាមរយៈការមានកាន់តែច្រើននូវបរិមាណ ស្រូវដែលប្រកបដោយគុណភាពខ្ពស់សម្រាប់ការហូបចុក ក៏ដូចជាសម្រាប់ការលក់ដូរ ។

### លក្ខខណ្ឌ ឬ ស្ថានភាពភូមិសាស្ត្រ

ព័ត៌មានក្នុងឯកសារបែបបទនេះ អាចយកទៅអនុវត្តបានសម្រាប់រាល់ទីតាំងភូមិសាស្ត្រក្នុងទូទាំងប្រទេស ។ វិធីសាស្ត្រទុកដាក់មួយចំនួនដែលមានភាពសមស្របទៅតាមសេចក្តីត្រូវការ និង លក្ខខណ្ឌផ្សេងៗ

ក្តារបស់កសិករត្រូវបានដាក់បញ្ចូល ។ ទោះជាបែបនេះក្តីភ្នាក់ងារផ្សព្វផ្សាយគួរតែជ្រើសរើសយកនូវវិធីសាស្ត្រផ្សព្វផ្សាយ ឬ អនុវត្តដោយផ្អែកទៅលើកម្រិតនៃការយល់ដឹងតាមមូលដ្ឋាន បរិមាណគ្រាប់ស្រូវដែលត្រូវទុកដាក់ និង រយៈពេលទុកដាក់ ។ល។

## សេចក្តីត្រូវការពលកម្ម

នៅពេលចាប់ផ្តើមទុកដាក់ មានកិច្ចការជាច្រើនដែលត្រូវការកម្លាំងពលកម្មច្រើន (ដែលជាទូទៅត្រូវបានអនុវត្តឡើងដោយសមាជិកស្ទើរតែទាំងអស់ក្នុងគ្រួសារ) ដូចជាការច្រូតកាត់ បោកបែន សម្អាត សម្ងួត រៀបចំ ឬ សាងសង់ជង្រុក បរិក្ខារ ឬ កន្លែងទុកដាក់ និង ការទុកដាក់ ។ បន្ទាប់ពីនោះមកកម្លាំងពលកម្មតែម្នាក់អាចនឹងមានភាពគ្រប់គ្រាន់ក្នុងការទទួលយក និង ប្រតិបត្តិនូវបច្ចេកទេសដែលមានរៀបរាប់ក្នុងឯកសារនេះ និង ក្នុងការថែរក្សាបរិក្ខារ និង ផលិតផលទុកដាក់ ។

## ស្ថានភាពសេដ្ឋកិច្ចរបស់កសិករដែលបានទទួលយកនូវបច្ចេកវិទ្យានេះ

កសិករទាំងឡាយដែលមានដីស្រែចាប់ពីកន្លះហិកតា ឬ ដែលត្រូវការទុកដាក់ស្រូវចាប់ពី ១ តោនឡើងទៅហើយដែលមានថវិកាសម្រាប់ចំណាយប្រមាណជា ២០ ទៅ ៤០ ម៉ឺនរៀល អាចនឹងទទួលយកទៅអនុវត្តនូវវិធីសាស្ត្រ និង បច្ចេកវិធីដែលមានរៀបរាប់ក្នុងឯកសារនេះ ។

## អនុសាសន៍ និង តម្រូវការពិសេសនានាផ្សេងទៀត

វាជាការសំខាន់ និង ចាំបាច់ខ្លាំងណាស់ដែលភ្នាក់ងារផ្សព្វផ្សាយកសិកម្មត្រូវស្វែងយល់ និង វិភាគអោយបានគ្រប់ជ្រុងជ្រោយអំពីដំណើរការ និង ប្រសិទ្ធិភាពនៃប្រព័ន្ធ ឬ វិធីសាស្ត្រថ្មី សម្រាប់លក្ខខណ្ឌនីមួយៗ ។ ការវិភាគមិនគ្រប់គ្រាន់ និង ការអនុវត្តន៍មិនសមស្របនូវវិធីសាស្ត្រ ឬ បច្ចេកវិទ្យាថ្មី សម្រាប់លក្ខខណ្ឌជាក់ស្តែងរបស់កសិករអាចនឹងធ្វើអោយមានការភ្ញាក់ផ្អើល និង ការមិនសម្រេចបានជោគជ័យក្នុងការបង្កើនកម្រិតជីវភាព ឬ សុខមាលភាពកសិករ ។

ជាទូទៅ កសិករនឹងទទួលយកទៅអនុវត្តនូវការកែលម្អ ឬ បច្ចេកទេសទុកដាក់ថ្មីណាដែលមិនសូវប្លែកខ្លាំងមិនសូវមានភាពសាំញ៉ាំ និង ពុំតម្រូវអោយមានការចំណាយប្រាក់កាសច្រើន ប៉ុន្តែមានការពន្យល់ច្បាស់លាស់ធ្វើអោយគាត់ងាយយល់ និង ងាយស្រួលអនុវត្ត ដើម្បីកាត់បន្ថយនូវការបាត់បង់ស្រូវរបស់គាត់ ។ ផ្ទុយទៅវិញគាត់ច្រើនតែមានភាពស្ទាក់ស្ទើរក្នុងការកែប្រែ ឬ ផ្លាស់ប្តូរទាំងស្រុងនូវវិធី ឬ របៀបទុកដាក់ស្រូវតាមទម្លាប់ ឬ ជាប្រពៃណីរបស់គាត់។

ជាឧទាហរណ៍ការបញ្ចូល ឬ ការទទួលយកទៅប្រតិបត្តិនូវបច្ចេកទេសទុកដាក់ថ្មីប្រាកដជានឹងធ្វើអោយការបាត់បង់មានតិចជាងមុន ប៉ុន្តែប្រសិនបើការចំណាយដើមទុនសម្រាប់ធ្វើអោយមានការផ្លាស់ប្តូរនោះមានកម្រិតខ្ពស់ពេកធៀបទៅនឹងបរិមាណផលចំណេញ និងការលើកទឹកចិត្តដែលទទួលបានពីការមិនបាត់បង់ (នយោបាយ ឬ របៀបកំណត់តម្លៃដោយមិនអោយតម្លៃទៅលើគុណភាព) កសិករ ឬ ភ្នាក់ងាររក្សាទុកដាក់ស្រូវនឹងពុំចាប់អារម្មណ៍អំពីការទទួលយកទៅអនុវត្តនូវបច្ចេកវិទ្យានោះឡើយ ។

នៅក្នុងការវិភាគតាមតម្លៃដើម និង ផលចំណេញ កត្តាមួយទៀតដែលត្រូវពិនិត្យពិចារណា គឺថាតើគ្រាប់ស្រូវ ដែលទុកដាក់នោះនឹងត្រូវបានយកទៅប្រើប្រាស់ជាស្បៀងអាហារក្នុងគ្រួសាររបស់កសិករផ្ទាល់ ឬមួយសម្រាប់លក់យកប្រាក់ ។ ក្នុងករណីដែលគ្រាប់ស្រូវគ្រាន់តែត្រូវបានទុកដាក់ដើម្បីការហូបចុកក្នុងគ្រួសារផ្ទាល់កសិករ ប្រាកដជាមានភាពស្ទាក់ស្ទើរក្នុងការចំណាយសោហ៊ុយបន្ថែមដើម្បីធ្វើអោយគុណភាពវាប្រសើរជាងមុន ស្ថានការណ៍នឹងមានភាពខុសពីនេះ ប្រសិនបើគ្រាប់ស្រូវត្រូវបានទុកដាក់សម្រាប់លក់ ជាពិសេសកាលណាថ្លៃលក់មានសភាពខ្ពស់ទាបខ្លាំងទៅតាមកម្រិតគុណភាពល្អ អាក្រក់របស់វា សមល្មមនឹងលើកទឹកចិត្តគាត់បាន ។

ដោយហេតុថា ការទទួលបាននូវអត្រាសំណើមសមស្រប គឺជាកត្តាគន្លឹះដើម្បីសម្រេចបាននូវជោគជ័យក្នុងការទុកដាក់គ្រាប់ស្រូវទាំងក្នុង និង ក្រោយពេលប្រមូលផល (រួមទាំងការទុកដាក់ផង) ហើយការប្រមាណអំពីអត្រាសំណើមទៅតាមការស្មាន និង បទពិសោធន៍ត្រូវបានសង្កេតឃើញថាពុំមានភាពច្បាស់លាស់ ឬ ទៀងទាត់ ធ្វើអោយការប្រើប្រាស់នូវបរិក្ខារវាស់សំណើមមានសារៈសំខាន់ជាទីបំផុត ហើយភ្នាក់ងារផ្សព្វផ្សាយចាំបាច់គួរតែមានបរិក្ខារនេះ ។

## ២. គោលការណ៍ណែនាំបច្ចេកទេស

### ២.១ មូលហេតុ ឬ ភាពចាំបាច់ក្នុងការបង្កើតឯកសារនេះ

នៅកម្ពុជា ស្រូវអង្ករគឺជាដំណាំស្បៀងដែលសំខាន់ជាងគេបំផុត ។ ទោះជាបែបនេះក្តី ដំណាំនេះតែងត្រូវបានកសិករដាំដុះតាមរដូវ ហើយនៅតំបន់ជាច្រើន ការប្រមូលផលអាចនឹងកើតមានតែម្តងក្នុងមួយឆ្នាំ ដែលតម្រូវអោយមានការទុកដាក់សម្រាប់រយៈពេលពី ១ ខែ រហូតដល់យូរជាង ១ ឆ្នាំ ។

ក្នុងវិស័យសេដ្ឋកិច្ច មុខងារដ៏សំខាន់ក្នុងការទុកដាក់ គឺដើម្បីទប់ស្កាត់នូវការប្រែប្រួលឡើងចុះនៃការផ្គត់ផ្គង់ និង តម្លៃ ។ ប្រសិនបើកសិករអាចទុកដាក់ស្រូវរបស់គាត់បានជោគជ័យ គាត់នឹងអាចប្រើប្រាស់បានកាន់តែមានប្រសិទ្ធិភាពនូវស្បៀងអាហារដែលគាត់មាន ហើយជាទូទៅគាត់អាចទទួលបានផលចំណេញច្រើនជាងការដែលគាត់ត្រូវលក់ស្រូវទាំងនោះភ្លាមបន្ទាប់ពីច្រូតកាត់រួច ។ ជាងនេះទៅទៀត ទីផ្សារជាច្រើន (ឧ. ទីផ្សារអន្តរជាតិ) តែងតែមានតម្រូវការគ្រាប់ស្រូវអង្ករដែលមានស្តង់ដារគុណភាពកាន់តែខ្ពស់ ។

វិធីសាស្ត្រទុកដាក់ស្រូវនៅកម្ពុជានៅតែត្រូវបានពិនិត្យ ឬសង្កេតឃើញថាមិនទាន់មានលក្ខណៈសមស្រប ដែលបង្កអោយមានការបាត់ និងខាតបង់ជាច្រើនដែលមិនគួរនឹងទទួលយកបាន ។ កសិករបានប្រឹងប្រែងតស៊ូពេញមួយរដូវដើម្បីដាំដុះ ថែទាំដាក់ជី ប្រយុទ្ធទល់នឹងជម្ងឺ និង សត្វល្អិតចង្រៃនានាព្រមទាំងធ្វើការច្រូតកាត់អោយទាន់ពេល ធ្វើយ៉ាងណាដើម្បីទទួលបាននូវទិន្នផលខ្ពស់ ប៉ុន្តែការបាត់បង់ និង ការខូចខាតនូវគ្រាប់ស្រូវអង្ករដែលជាស្បៀងអាហារដែលគាត់ខំរកបានមកហើយនោះ បែរជាបន្ថែមនូវបញ្ហាដែលគាត់កំពុងមានស្រាប់ទៅវិញ ។ អាស្រ័យហេតុនេះ ការប្រើប្រាស់អោយបានជាអតិបរិមានូវផលិតផលស្បៀងដែលមានស្រាប់ គឺជា

កិច្ចការដ៏មានសារៈសំខាន់ ហើយអាទិភាពត្រូវតែផ្តល់ដល់កិច្ចការពារទប់ស្កាត់នូវការបាត់បង់ និង ខូចខាតទាំងឡាយនោះ ។

គ្រាប់ស្រូវអង្ករមានគុណភាពល្អ ឬ ខ្ពស់បំផុតនៅពេលច្រូតកាត់ ។ ការទុកដាក់មិនអាចនឹងធ្វើអោយកើនឡើងនូវកម្រិតគុណភាពនោះបានទេ តែផ្ទុយទៅវិញលក្ខខណ្ឌ និង រយៈពេលទុកដាក់អាចនឹងមានឥទ្ធិពលខ្លាំងដល់ការថយចុះនូវគុណភាពនោះ ។ នៅក្រោមលក្ខខណ្ឌទុកដាក់ដែលមិនមានភាពសមស្របគុណភាពគ្រាប់ស្រូវអាចនឹងថយចុះយ៉ាងលឿន សូម្បីតែក្នុងរយៈពេលពី ២ ទៅ ៣ ម៉ោង ។

ហេតុនេះ គឺជាការសំខាន់ដែលភ្នាក់ងារត្រូវបង្ហាញ និង ផ្សព្វផ្សាយនូវចំណេះដឹង និង ព័ត៌មានទាំងឡាយដែល មាននៅក្នុងឯកសារនេះទៅអោយដល់កសិករ ធ្វើយ៉ាងណាដើម្បីអោយគាត់អាចកាត់បន្ថយបាននូវការបាត់បង់ និងការខូចខាតនានាព្រមទាំងអាចទទួលបាននូវផលចំណេញកាន់តែច្រើនអំពីផលិតផលដែលគាត់ប្រមូលបាន ឬ អំពីស្បៀងអាហារដែលគាត់មាន ។

## ២.២ ការបាត់បង់នៅក្នុងពេលទុកដាក់

កសិករកម្ពុជាមានទម្លាប់ ឬ ប្រពៃណីទុកដាក់ស្រូវនៅក្នុងជង្រុក ឬ បាវ ។ ដោយពុំបានផ្តល់នូវការយកចិត្តទុកដាក់ និង ពុំមានការយល់ដឹងគ្រប់គ្រាន់ការបាត់បង់ក្នុងកម្រិតដ៏ខ្ពស់តែងត្រូវបានកើតមានចំពោះផលិតផលនោះក្នុងអំឡុងពេលទុកដាក់ ។ កាត់បាត់បង់ទាំងនោះមានទាំង ២ ប្រភេទគឺបរិមាណ និង គុណភាព ។

### ២.២.១ ការបាត់បង់ជាបរិមាណ

ការបាត់បង់ជាបរិមាណតែងបណ្តាលមកពីការជ្រុះកំពប់ពីបាវ ឬ បរិក្ខារនានា និង ដោយសារការស៊ី ឬ ការ បំផ្លាញអោយខូចដោយសត្វចង្រៃនានាដូចជាកណ្តុរសត្វស្លាប និង សត្វល្អិត ។ កណ្តុរធំមួយស៊ីស្រូវអស់ពី ៥ ទៅ ៩ គីឡូក្រាម កណ្តុរដែលនៅតាមដំបូលផ្ទះស៊ីស្រូវអស់ពី ៣ ទៅ ៤ គីឡូក្រាម និង កណ្តុរតូចៗស៊ីស្រូវអស់ប្រមាណជា ១ គីឡូក្រាម ក្នុងមួយឆ្នាំ ។ ការស្រកទម្ងន់ដែលបណ្តាលមកពីការស្រកសំណើមមិនគួរចាត់ទុកថាជាការបាត់បង់ឡើយ ។

### ២.២.២ ការបាត់បង់គុណភាព

ការបាត់បង់គុណភាព កើតមានក្នុងទម្រង់ជាច្រើន រួមមាន

- ការប្រែប្រួលពណ៌សម្បុរ (ឧ. ការឡើងក្រម៉ៅនៃគ្រាប់ស្រូវ ឬ ការឡើងពណ៌លឿងនៃគ្រាប់អង្ករ)
- ការប្រែប្រួលក្លិន (ឧ. ពីក្រអូបប្រហើរទៅជាផ្អូរ)
- ការប្រែប្រួលរសជាតិ
- ការថយចុះនូវសារធាតុចិញ្ចឹម (ការថយចុះនូវប្រូតេអ៊ីន និង វីតាមីន)
- ការថយចុះនូវគុណភាពអង្ករ និង គុណភាពបាយ
- ការកើតមានជម្ងឺផ្សិត និង

○ ការថយចុះនូវសមត្ថភាពដំណុះនៃគ្រាប់ស្រូវពូជ ។ល។

ជាញឹកញាប់ការប្រែប្រួល ឬ ការថយចុះគុណភាពដូចដែលបានរៀបរាប់នេះតែងកើតមានព្រមៗគ្នា ដែលតាមធម្មតាវាក៏នឹងបណ្តាលអោយមានការបាត់បង់ជាបរិមាណផងដែរ ។

ការបាត់បង់គុណភាពធ្វើអោយប៉ះពាល់ជាខ្លាំងដល់តម្លៃនៅលើទីផ្សារ ។ ជាឧទាហរណ៍ អតិថិជនងាយនឹងបដិសេធមិនទិញ ឬ ទិញក្នុងតម្លៃថោកនូវស្រូវអង្ករដែលបានរងការយាយីបំផ្លាញ ។ គ្រាប់ស្រូវដែលរងការបំផ្លាញ ពីសំណាក់សត្វល្អិត តែងតែមានលាយឡំទៅដោយកាកសំណល់នានាដែលធ្វើអោយកើនឡើងនូវធូលី ឬ កំទិចកំទីនានា ។ ជាងនេះទៅទៀតគ្រាប់ស្រូវតែងមានប្រហោង និង ឡើងពណ៌ក្រម៉ៅ ។ បាយដែលដាំពីស្រូវអង្ករបែបនោះអាចនឹងមានក្លិន និង រសជាតិពុំល្អ ។

ដើម្បីជៀសវាងនូវបញ្ហាទាំងនោះ ភ្នាក់ងារផ្សព្វផ្សាយត្រូវតែអនុវត្តបង្ហាញដល់កសិករអំពីផលប្រយោជន៍នានាដែលអាចនឹងទទួលបានអំពីការទទួលយកទៅប្រើប្រាស់នូវវិធីសាស្ត្រដូចដែលមានរៀបរាប់ខាងក្រោម ៖

## ២.៣ ការគ្រប់គ្រងគ្រាប់ស្រូវនៅមុនពេលទុកដាក់

ភ្នាក់ងារផ្សព្វផ្សាយត្រូវតែអនុវត្តបង្ហាញនូវបច្ចេកទេសច្រូតកាត់គ្រប់គ្រង និង ហាលសម្ងួតដែលផ្តល់សុវត្ថិភាពដល់គ្រាប់ស្រូវ ដើម្បីជៀសវាងនូវការខូចខាតនៅមុនពេលទុកដាក់ ។

### ២.៣.១ ការប្រមូលផលក្នុងពេលដ៏ត្រឹមត្រូវ

ដើម្បីកាត់បន្ថយអោយដល់កម្រិតអប្បបរមានូវការបាត់បង់ដោយអាកាសធាតុមិនល្អ ការជ្រុះកំពប់ និង ការ ប្រេះគ្រាប់ ស្រូវគួរតែត្រូវបានច្រូតកាត់នៅក្នុងកាលវេលា ឬ នៅពេលដែលវាមានអត្រាសំណើមសមស្រប ។ ការទុកអោយស្រូវឡើងទុំញ្ជោសនៅក្នុងស្រែ ស្ថិតក្រោមការប្រែប្រួលនៃសំណើម និង សីតុណ្ហភាពបរិយាកាស អាចជាមូលហេតុដ៏សំខាន់នៃការជ្រុះកំពប់ និង ការប្រេះស្រាំគ្រាប់ (រូបទី ១) ។



*រូបទី ១. ការប្រេះគ្រាប់អង្ករដែលពិនិត្យឃើញដោយពន្លឺពណ៌ក្រហម (ប្រភព IRRI)*

អត្រាសំណើមសមស្របសម្រាប់ការច្រូតកាត់ដែលនៅចន្លោះពី ២០ ទៅ ២៥ % មិនត្រឹមតែផ្តល់នូវទិន្នផលស្រូវខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងធ្វើអោយទទួលបាននូវអត្រាអង្ករខ្ពស់ពីការកិនផងដែរ ។ ប្រសិនបើស្រូវត្រូវបានច្រូតកាត់នៅពេលដែលវាមានអត្រាសំណើមខ្ពស់ជាងនេះ កសិករអាចនឹងឃើញថាអត្រាអង្ករដើមដែល

ទទួលបានពីការកិនមានការថយចុះ ដោយសារវត្តមាននៃគ្រាប់ស្រូវដែលនៅមិនទាន់ទុំ ឬ នៅសើ្សរទឹក ។ ផ្ទុយទៅវិញ ប្រសិនបើកសិករទុកស្រូវអោយស្ងួតជ្រុល គឺធ្វើអោយវាមានអត្រាសំណើមទាបជាង ១៥ % នៅក្នុងស្រែ លទ្ធភាពក្នុងការថយចុះនូវអត្រាអង្ករដើមក៏មានច្រើនណាស់ដែរ ។




*រូបទី ២. បរិក្ខារវាស់អត្រាសំណើមគ្រាប់ធញ្ញជាតិមួយចំនួន*

ក្នុងករណីដែលពុំអាចរកបរិក្ខារវាស់សំណើម (រូបទី ២) បានកសិករគួរសម្រេចធ្វើការច្រូតកាត់ដោយផ្អែកទៅលើ ៖

- <u>ពណ៌របស់គ្រាប់ស្រូវ:</u> នៅពេលដែលគ្រាប់ស្រូវពី ៨០ ទៅ ៨៥ % មានពណ៌ដូចចំបើង (ជាសញ្ញាបញ្ជាក់ថាវាទុំគ្រប់គ្រាន់) ហើយគ្រាប់ស្រូវដែលនៅផ្នែកខាងក្រោមនៃកួរស្ថិតក្នុងដំណាក់កាលដាក់ម្សៅរឹង ។
- <u>ចំនួនថ្ងៃក្រោយពេលស្រូវចេញផ្កា:</u> ប្រមាណជា ៣០ ថ្ងៃ
- <u>ភាពរឹងនៃគ្រាប់:</u> គ្រាប់ស្រូវគួរតែមានសភាពរឹង ប៉ុន្តែមិនស្រួយនៅពេលយកវាទៅខាំ ។

### ២.៣.២ ការបោកបែនជាបន្ទាន់ និងពុំធ្វើអោយប៉ះទង្គិចខ្លាំង

កសិករគួរតែអនុវត្តការបោកបែនស្រូវដែលច្រូតកាត់ហើយជាបន្ទាន់ ឬ អោយឆាប់តាមដែលអាចធ្វើបាន កាលណាកណ្តាប់ស្រូវត្រូវបានទុកចោលយូរជាគំនរ គ្រាប់ស្រូវនឹងត្រូវប្រឈមជាមួយសត្វល្អិត សត្វស្លាប កណ្តុរ ជម្ងឺ និង ការកើតផ្សិត ។ វាក៏អាចនឹងសើមឡើងវិញ ដែលបណ្តាលអោយវាប្រេះ ហើយបាក់ខ្ទេចនៅពេលបោកបែន និង នៅពេលកិន ។ ជាមួយគ្នានោះ គ្រាប់ស្រូវអាចឡើងពណ៌ក្រម៉ៅ ហើយគ្រាប់អង្ករដែលកិនបាននឹងឡើងពណ៌លឿង (រូបទី ៣) ។ ការដុះគ្រាប់ដែលមិនចង់បានក៏អាចនឹងកើតមានឡើងផងដែរ ។



*រូបទី ៣. ការឡើងពណ៌លឿងនៃគ្រាប់អង្ករដោយសារការឡើងកំដៅនៃគ្រាប់ស្រូវនៅមុនពេលសម្ងួត និង នៅក្នុងពេលទុកដាក់ (ប្រភព IRRI)*

ការបោកបែន ឬ ការប្រឡេះគ្រាប់ស្រូវចេញពីចំបើងដោយបែននឹងជើងគឺជាវិធីដែលប្រសើរជាងគេបំផុតដែលកសិករគួរអនុវត្ត ប្រសិនបើគាត់ចង់អោយគ្រាប់ស្រូវមានគុណភាពខ្ពស់បំផុត ដរាបណាស្រូវដែលត្រូវបោកបែនពុំមានបរិមាណច្រើនហួស (ក្នុងមួយម៉ោងមនុស្សម្នាក់អាចនឹងបែនបានស្រូវពី ១០ ទៅ ៣០ គីឡូក្រាម អាស្រ័យទៅតាមពូជស្រូវកម្រិតទុំ សំណើម និង ទិន្នផលស្រូវ) ។ កសិករក៏អាចប្រើប្រាស់គោក្របី ឬ យានយន្តផ្សេងៗដើម្បីបញ្ជាន់កណ្តាប់ស្រូវបានដែរ (អត្រាគ្រាប់ស្រូវដែលទទួលបានអាចមានពី ២០០ ទៅ ៣០០ គីឡូក្រាមក្នុងមួយម៉ោង) ប៉ុន្តែតោងប្រយ័ត្នជៀសវាងនូវការធ្វើអោយបាក់ ឬ កប់គ្រាប់ស្រូវនៅក្នុងដី (ក្នុងលានបញ្ជាន់) ។ ការបោកស្រូវដោយវាយផ្ទប់នឹងគ្រែរនាប ឬ ក្តារបោកអាចនឹងធ្វើបានក្នុងសន្ទុះលឿនជាងការបែន ប៉ុន្តែអាចនឹងធ្វើអោយបាក់គ្រាប់ស្រូវច្រើនជាងដែរ ។

ប្រសិនបើស្រូវត្រូវបានបោកបែនដោយម៉ាស៊ីន ត្រូវតែចាប់អារម្មណ៍ថា ៖

- អត្រាសំណើមគ្រាប់ស្រូវ និង ការកែសម្រួលម៉ាស៊ីនអាចមានឥទ្ធិពលដល់ដំណើរការរបស់ម៉ាស៊ីន សមត្ថភាពបោក និង គុណភាពគ្រាប់ស្រូវ ។ អត្រាសំណើមសមស្របសម្រាប់ការបោកបែនដោយម៉ាស៊ីនគឺនៅចន្លោះពី ២០ ទៅ ២៥ %
- កាលណាគ្រាប់ស្រូវសើមពេក ការបោកបែននឹងយឺត ហើយអាចបណ្តាលអោយរលាត់ដាច់សម្បកអង្កាម ។
- កាលណាគ្រាប់ស្រូវស្ងួតពេក ការបោកបែនអាចធ្វើអោយប្រេះស្រាំគ្រាប់ច្រើន
- ចុងធ្មេញត្បាល់គួរតែត្រូវកែសម្រួលអោយវិលក្នុងល្បឿនពី ១២ ទៅ ១៦ ម៉ែត្រក្នុងមួយវិនាទី ឬ ប្រមាណជា ៦០០ ជុំក្នុងមួយនាទី ។ ល្បឿនវិលលឿនជាងនេះនឹងធ្វើអោយគ្រាប់ស្រូវខូចខាតច្រើន

ហើយល្បឿនវិលយឺតជាងនេះអាចធ្វើអោយមាននៅសល់គ្រាប់ស្រូវបោក ឬ ប្រឡេះមិនអស់ចេញពីកួរ ។

### ២.៣.៣ ការសម្អាតសម្រស់

តាមធម្មតា គ្រាប់ស្រូវដែលទទួលបានពីការបោកបែនមានលាយឡំទៅដោយសម្រាម និង កំទិចកំទីផ្សេងៗ ដែលគួរតែត្រូវសម្អាតចេញអោយបានឆាប់តាមដែលអាចធ្វើបាន នៅក្នុង និង ក្រោយពេលបោកបែនហើយ អោយបានប្រាកដនៅមុនពេលទុកដាក់ ។ គ្រាប់ស្រូវដែលស្អាតអាចទុកដាក់បានដោយជោគជ័យជាងគ្រាប់ស្រូវដែលមិនស្អាត ។ សម្រាមដែលនៅលាយឡំជាមួយអាចជាប្រភពនៃការឃាយីបំផ្លាញនៃសត្វល្អិត និង ការឡើងកំដៅ។

កសិករអាចសម្អាតគ្រាប់ស្រូវបានដោយវិធីរោយតាមទម្លាប់ ឬ ដោយប្រើបរិក្ខារជំនួយដូចដែលមានបង្ហាញក្នុងរូបទី ៤ ។




*រូបទី ៤. ការសម្អាតគ្រាប់ស្រូវដោយវិធីរោយ ឬ ដោយប្រើប្រាស់បរិក្ខារជំនួយមួយចំនួន*

### ២.៣.៤ ការហាលសម្ងួត

នៅពេលច្រូតកាត់ អត្រាសំណើមគ្រាប់ស្រូវអាចស្ថិតក្នុងចន្លោះពី ១៨ ទៅ ២៨ % ។ សំណើមបែបនេះមាន កម្រិតខ្ពស់ហួស មិនអាចអោយការទុកដាក់អាចនឹងប្រព្រឹត្តទៅដោយសុវត្ថិភាពទេ ។ ការទុកដាក់ស្រូវសើមនឹងធ្វើអោយកើតមានជម្ងឺផ្សិត និង សត្វល្អិត ។ ដូចនេះ គឺជាការសំខាន់ដែលត្រូវបន្ថយអត្រាសំណើមនោះអោយចុះមកនៅត្រឹម ១៤ % ឬ ទាបជាង ដោយការហាលសម្ងួត (ជាឧទាហរណ៍ ១៤ % សម្រាប់ការទុកដាក់ស្រូវស្បៀង ១៣ % សម្រាប់ការទុកដាក់ស្រូវពូជ និង ៩ % សម្រាប់ការរក្សាទុកពូជក្នុងរយៈពេលយូរ) ។

ដោយសារថាម៉ាស៊ីនសម្ងួតពុំទាន់ត្រូវបានយកមកប្រើប្រាស់ក្នុងប្រទេសនេះនៅឡើយ កសិករចាំបាច់ត្រូវហាលស្រូវរបស់គាត់ក្រោមកំដៅថ្ងៃ ។ អាស្រ័យទៅតាមអត្រាសំណើមដើមនៃគ្រាប់ស្រូវរបៀបហាល និង លក្ខខណ្ឌអាកាសធាតុ ការហាលសម្ងួតបែបនេះអាចត្រូវការពេលពី ១ ទៅ ៣ ថ្ងៃ ។ ដើម្បីការពារកុំអោយគ្រាប់

ស្រូវមានធូលី និង ស្រូបសំណើមឡើងវិញ ត្រូវហាលវានៅលើសំពត់កៅស៊ូ ឬ កន្ទេល ។ គួរពង្រាយគ្រាប់ស្រូវដោយជៀសវាងកុំធ្វើអោយវាមានកម្រាស់ក្រាស់ជាង ៤ សង់ទីម៉ែត្រ ដើម្បីធ្វើអោយគ្រាប់ស្រូវអាចទទួលបាននូវការសម្ងួតស្មើសព្វល្អ ។ គួររឺត្រឡប់ស្រូវរៀងរាល់កន្លះម៉ោង ឬ រៀងរាល់ម៉ោង ។ ជាការសំខាន់ដែរ ដែលត្រូវសម្អាតទីលានហាលអោយបានស្អាត ។

គួរគ្របគ្រាប់ស្រូវនៅពេលថ្ងៃត្រង់ ឬ នៅពេលដែលមានថ្ងៃក្តៅខ្លាំង ព្រោះថាការឡើងកំដៅខ្ពស់ជាង ៤៣ អង្សារសេ អាចធ្វើអោយស្រូវងាយប្រេះ និង គ្រាប់ពូជលែងសូវដុះ ។

*<u>បញ្ជាក់ ៖</u> ដើម្បីបន្ថយ ឬ ការពារមិនអោយកើតមានការឡើងកំដៅនៅក្នុងជង្រុក ឬ កន្លែងទុកដាក់ កសិករគួរតែធ្វើអោយស្រូវចុះត្រជាក់សិនបន្ទាប់ពីហាលសម្ងួតហើយ ដោយទុកវានៅក្នុងម្លប់មួយរយៈ មុននឹងយកវាទៅទុកដាក់ ។*

### ២.៣.៥ កំណជាញើស

ការទុកដាក់ជាគំនរក្នុងជង្រុក ឬ បរិក្ខារទុកដាក់បែបប្រពៃណី អាចនឹងធ្វើអោយគ្រាប់ស្រូវប្រឈមជាមួយនឹងការឡើងចុះសំណើមនៃបរិយាកាស ទៅតាមរដូវ និង ទៅតាមលក្ខខណ្ឌអាកាសធាតុ ។ ការប្រែប្រួលនូវអត្រាសំណើមអាចបណ្តាលអោយគ្រាប់ស្រូវឡើងចាស់ ហើយថយចុះគុណភាព ។

ប្រសិនបើខ្យល់នៅក្នុងកន្លែងទុកដាក់ក្តៅ ហើយចុះត្រជាក់ភ្លាមៗ វានឹងបាត់បង់សមត្ថភាពក្នុងការរក្សាសំណើម ហើយកំណជាញើសនឹងកើតមាន ។ កំណញើសអាចនឹងកើតមានផងដែរ កាលណាបរិយាកាសនៅខាងក្នុង និង ខាងក្រៅកន្លែងទុកដាក់មានសីតុណ្ហភាពខុសគ្នាខ្លាំង ។ ឧទាហរណ៍ដ៏សាមញ្ញមួយគឺនៅពេលដែលផ្ទៃជញ្ជាំង ខាងក្រៅឡើងកំដៅ ឬ ចុះត្រជាក់ទៅតាមពេលវេលាថ្ងៃ និង យប់ ។

ហេតុនេះ កំណញើសកើតមាននៅក្នុងកន្លែងទុកដាក់ភាគច្រើននៅក្បែរជញ្ជាំង និង ពីក្រោមដំបូល (ជាពិសេសនៅពេលដែលជញ្ជាំង និង ដំបូលនោះធ្វើអំពីបន្ទះដែក ស័ង្កសី ឬ សំពត់កៅស៊ូ) ហើយដំណក់ញើសទាំងនោះ នឹងស្រក់ចុះមកលើគ្រាប់ស្រូវ ។ កំណញើសក៏អាចនឹងកើតមាននៅស្រទាប់ខាងលើបំផុតនៃស្រូវក្នុងអំឡុងពេលទុកដាក់ទោះបីជាគ្រាប់ស្រូវនោះត្រូវបានហាលសម្ងួតអោយស្ងួតគ្រប់គ្រាន់ហើយក៏ដោយ ។ ហេតុការណ៍នេះនឹងធ្វើអោយគ្រាប់ស្រូវឡើងសើមដែលបណ្តាលអោយកើតមានជម្ងឺផ្សិត និង ការដុះគ្រាប់ដែលមិនចង់បាន ។

កំណញើសក៏អាចនឹងកើតមានផងដែរ ប្រសិនបើគ្រាប់ស្រូវត្រូវបានទទួលរងនូវការយាយីបំផ្លាញខ្លាំងពីសំណាក់សត្វល្អិត ។ ការដកដង្ហើមនៃគ្រាប់ស្រូវ និងសត្វល្អិតបណ្តាលអោយកើនឡើងនូវកំដៅ និង សំណើមដែលជាហេតុបង្កអោយមាន " ចំណុចក្តៅ " ។ នៅពេលដែល "ចំណុចក្តៅ" នេះឡើងកំដៅខ្ពស់ជាង ៤០ អង្សារសេ សត្វល្អិតនឹងពុំអាចរស់នៅជិតៗនោះបាន ហើយចេះតែផ្លាស់ទីទៅរកកន្លែងត្រជាក់ បណ្តាលអោយ "ចំណុចក្តៅ " នោះចេះតែពង្រាយទៅកន្លែងផ្សេងទៀត (រូបទី ៥) ។




*រូបទី ៥. ចំណុចក្តៅ និង ការខូចខាតដែលទាក់ទងនានា*

## ២.៣.៦ កិច្ចការពារទល់នឹងសត្វកណ្តុរ

ដើម្បីកុំអោយកណ្តុរឡើងចូលទៅក្នុងជង្រុក ឬ កន្លែងទុកដាក់បាន គួរតែដាក់អោយមានរបាំងការពារនៅលើសសរ ឬ បង្គោលជង្រុក (រូបទី ៦) ឬ ពាសជង្រុកដោយសំណាញ់ដែក (រូបទី ១៣) ។ កណ្តុរស៊ីស្រូវ ហើយកាត់បំផ្លាញសម្បកបាវ និង បរិក្ខារទុកដាក់ផ្សេងៗ ប៉ុន្តែវាតែងធ្វើអោយគ្រាប់ស្រូវឡើងកខ្វក់ដោយទឹកនោម និង លាមករបស់វាច្រើនជាងបរិមាណដែលវាស៊ីបំផ្លាញនោះទៅទៀត ។ វាក៏ជាភ្នាក់ងារនាំចម្លងជម្ងឺផ្សេងៗ ដែលអាចធ្វើអោយប៉ះពាល់ដល់សុខភាពមនុស្ស ។



*រូបទី ៦. របាំងការពារកណ្តុរដែលគួរដាក់នៅលើបង្គោល ឬ សសរជង្រុក*

ដើម្បីទប់ស្កាត់កណ្ដុរ កសិករគួរចិញ្ចឹមឆ្មា និង អនុវត្តវិធីដាក់អង្គប់ផ្សេងៗ ។ ការប្រើប្រាស់អង្គប់អាចនឹងមានប្រសិទ្ធិភាពតែនៅពេលដែលការបំផ្លាញមានកម្រិតទាប ។ អង្គប់កណ្ដុរមានច្រើនប្រភេទប៉ុន្តែមានតែមួយចំនួនតូចប៉ុណ្ណោះដែលបំពេញមុខងារបានល្អ ។

### *អង្គប់ទ្រុង*

អង្គប់ទ្រុងដែលបង្ហាញក្នុងរូបទី ៧ ត្រូវបានគេរាយការណ៍ថាបានបំពេញមុខងារយ៉ាងល្អដោយពុំមានភ្លាត់មានសុវត្ថិភាពក្នុងការប្រើប្រាស់ ហើយមានភាពសាមញ្ញដែលអាចអោយកសិករផលិតដោយខ្លួនឯងបាន ។ បន្ទាប់ពីដាក់តម្លើង និង បិទនុយហើយ អង្គប់នេះគួរត្រូវបានយកទៅដាក់អោយមុខរបស់វាបែរទៅជញ្ជាំង (ប្រយត្ន័កុំអោយប៉ះ) របង ឬ ផ្លូវកណ្ដុរ ធ្វើយ៉ាងណាអោយកណ្ដុរឆ្លងកាត់ពីក្រោមសន្ទះបើកក្នុងចន្លោះអង្គប់ និង ជញ្ជាំងនោះ ។ ត្រូវធ្វើអោយបានប្រាកដថាពុំមានសម្រាម ឬ វត្ថុផ្សេងៗដែលទើសទែងមិនអោយគន្លឹះ និង សន្ទះរបស់អង្គប់អាចភ្លាត់ និង បិទជិតស្រួលបួលបាន ។



*រូបទី ៧. អង្គប់កណ្ដុរប្រភេទទ្រុង*

### *អង្គប់ធុង*

អង្គប់ធុង (រូបទី ៨) ក៏មានលក្ខណៈសាមញ្ញ ហើយត្រូវបានគេរាយការណ៍ថាមានប្រសិទ្ធិភាពខ្ពស់ និង ត្រូវបាន គេប្រើប្រាស់យ៉ាងទូលំទូលាយ ។ ដើម្បីធ្វើវា ៖

- គេត្រូវការធុងចំណុះប្រមាណជា ២០ លីត្រ ឬ ក្រឡធំដែលអាចដាក់ទឹកបាន
- កប់ធុង ឬ ក្រឡនោះនៅក្បែររន្ធ ឬ កន្លែងដែលកណ្ដុរឆ្លងកាត់
- យកពោតមួយផ្លែមកកាត់ចុងដើមចេញ ហើយស៊កលួសសរសៃធំ ឬ សរសៃដែកដែលមានប្រវែងប្រមាណជា ១ ម៉ែត្រចូល ។ ត្រូវធ្វើយ៉ាងណាអោយផ្លែពោតនោះអាចវិលបានដោយស្រួល
- ធ្វើអ្វីទប់អោយផ្លែពោតនោះនៅចំកណ្ដាលលួស ឬ សរសៃដែកនោះ
- ពត់លួស ឬ សរសៃដែកនោះដូចបង្ហាញក្នុងរូប ហើយសង្កត់វាចូលទៅក្នុងដីនៅសងខាងមាត់ធុង ឬ ក្រឡនោះអោយជាប់
- ចាក់ទឹកចូលទៅក្នុងធុង ឬ ក្រឡនោះអោយមានជម្រៅប្រមាណជា ១៥ សង្ទីម៉ែត្រ (មួយតឹកកន្លះ)
- រៀងរាល់ល្ងាច ត្រូវយកនុយទៅលាប ឬ បិទភ្ជាប់ជាមួយផ្លែពោតនោះ ហើយ

- ស្រង់យកកណ្ដុរដែលធ្លាក់ចូលទៅក្នុងធុង ឬ ក្រឡនោះរៀងរាល់ព្រឹក ។ អង្គប់ប្រភេទនេះ បំពេញមុខងារបានល្អបំផុតក្នុងរាត្រីខ្មៅ ។



*រូបទី ៨. អង្គប់កណ្ដុរប្រភេទធុង*

### *អង្គប់វាយផ្ទប់*

អង្គប់ប្រភេទនេះ (រូបទី ៩) អាចយកទៅប្រើប្រាស់បានដើម្បីចាប់កណ្ដុរ ។ គួរតែប្រើវាពី ២ ទៅ ៣ សម្រាប់ ដាក់មួយកន្លែង ដើម្បីធ្វើយ៉ាងណាអោយកណ្ដុរមិនអាចជាន់ខុសគន្លឹះភ្លាត់ ។ កាលណាជាន់ខុសកន្លែងគន្លឹះអាចភ្លាត់តែមិនវាយជាប់កណ្ដុរ ហើយធ្វើអោយវាអាចផ្អើល ។ ដោយសារថាអង្គប់ប្រភេទនេះមានគ្រោះថ្នាក់វាគួរតែត្រូវបានដាក់នៅកន្លែងណាដែលកូនក្មេង ឬ សត្វដែលចិញ្ចឹមមិនអាចឆ្លងកាត់បាន ។



*រូបទី ៩. អង្គប់វាយផ្ទប់*

### *អង្គប់ប្រើជ័រស្អិត*

ក្នុងកាលៈទេសៈខ្លះអង្គប់ជ័រស្អិតអាចត្រូវបានគេប្រើប្រាស់ដើម្បីចាប់សត្វកណ្ដុរទាំងរស់ ដោយជៀសវាងការធ្វើអោយវាងាប់ ហើយស្អុយរលួយចោលក្លិនមិនល្អ ។ អង្គប់ប្រភេទនេះគួរដាក់នៅតាមផ្លូវឆ្លងកាត់របស់កណ្ដុរ គឺនៅចន្លោះរន្ធ ឬ សម្បុក និង ស្បៀងអាហាររបស់វា ។

ជាការសំខាន់ដែលត្រូវដឹងថា កណ្ដុរច្រើនផ្អើលជាមួយនឹងរបស់ ឬ វត្ថុណាដែលថ្មី ឬ ប្លែកសម្រាប់វា ហើយការយកអង្គប់ទៅដាក់ចោលដោយមិនតម្លើងនៅកន្លែងថ្មីមួយពី ១ ទៅ ២ សប្ដាហ៍ នឹងធ្វើអោយលទ្ធភាព

ចាប់ កណ្តុរបានអាចកើនឡើង ព្រោះថាវានឹងលែងផ្អើល ។ ដល់ពេលនោះ គួរដាក់តម្លើងអង្គប់អោយច្រើនតាមដែលអាចធ្វើបានដើម្បីចាប់កណ្តុរអោយបានច្រើននៅមុនពេលដែលវាផ្អើល ។ វិធីបែបនេះឈ្មោះថាការចាប់កណ្តុរជាក្រុម គឺជាការចាប់អោយបានច្រើនជាងកម្រិតដែលវាអាចបង្កើតកូនចៅបាន និង នៅមុនពេលដែលវាផ្អើលលែងហ៊ានមកជិតអង្គប់ ។

**គួរជៀសវាងកុំប្រើប្រាស់ថ្នាំពុលដើម្បីសម្លាប់សត្វកណ្តុរ** ព្រោះថាក្មេង ឬ សត្វផ្សេងទៀតអាចច្រឡំស៊ី ។ មួយ វិញទៀត កណ្តុរដែលត្រូវថ្នាំពុលអាចនឹងងាប់នៅកន្លែងដែលពិបាកនឹងយកចេញ ឬ ពិបាកសម្អាត ហើយធ្វើអោយមានក្លិនអាក្រក់ ។

## ២.៤ ជម្រើស ឬ វិធីទុកដាក់បែបថ្មី

កសិករអាចសម្រេចជ្រើសរើសនូវវិធីទុកដាក់ស្រូវ ដោយដាក់ជាគំនរក្នុងជង្រុក ក្នុងបាវ ឬ បរិក្ខារទុកដាក់ដែលអាចបិទជិតអាស្រ័យទៅតាមសេចក្តីត្រូវការរបស់គាត់ និង ទៅតាមសម្ភារៈដែលអាចរកបាន ប៉ុន្តែតោងប្រយ័ត្នជាមួយនឹងបញ្ហានានាដូចដែលមានរៀបរាប់ខាងក្រោម ។

### ២.៤.១ ការទុកដាក់ជាគំនរ ឬ ដោយចាក់ធារ

ជាមួយនឹងវិធីនេះគ្រាប់ស្រូវត្រូវបានចាក់ធារចូលទៅក្នុងជង្រុក ឬ ក្នុងបរិក្ខារទុកដាក់ដោយផ្ទាល់តែម្តង វិធីនេះមានភាពសាមញ្ញ អាចធ្វើទៅបានរហ័ស ហើយចំណាយអស់កម្លាំងពលកម្មតិច ប៉ុន្តែកសិករចាំបាច់ត្រូវមានការប្រុងប្រយ័ត្នអោយបានច្រើនដើម្បីទប់ស្កាត់នូវការបាត់បង់ ។ ជង្រុកដែលកសិករធ្លាប់ប្រើតាមទម្លាប់ដែលធ្វើអំពីឈើ បន្ទះឬស្សី ដីឥដ្ឋ អាចនឹងទទួលរងនូវការយាយីបំផ្លាញពីសំណាក់សត្វល្អិត និង កណ្តុរ ។

លក្ខខណ្ឌនៃបរិក្ខារទាំងនេះច្រើនតែពុំមានលក្ខណៈសមស្រប ដែលអាចអោយសំណើម និង សត្វចង្រៃអាចជ្រៀតចូលបានយ៉ាងស្រួល ។




*រូបទី ១០. ការដកដង្ហើមនៃគ្រាប់ធញ្ញជាតិ*

ដោយសារថាគ្រាប់ស្រូវដែលកំពុងទុកដាក់នៅមានជីវិត ហើយដកដង្ហើមវាបង្កអោយមានឧស្ម័នកាបូនិក ($CO_2$) ក៏ដូចជាទឹក និង កំដៅ ដូចដែលមានបង្ហាញក្នុងរូបទី ១០ ។ ប្រសិនបើពុំមានខ្យល់ថ្មី ឬ ពុំមានខ្យល់បក់

ឆ្លងកាត់គ្រប់គ្រាន់ទេនោះ គ្រាប់ស្រូវក្នុងគំនរនឹងឡើងកំដៅយ៉ាងឆាប់រហ័ស ជាពិសេសនៅពេលដែលអាកាសធាតុមានសភាពក្តៅហើយសើម (សំណើមបរិយាកាសខ្ពស់)។ លក្ខខណ្ឌបែបនេះនៅក្នុងកន្លែងទុកដាក់នឹងបង្កអោយមានភាពសមស្របបំផុតសម្រាប់ការកើតឡើងនូវកត្តាចង្រៃនានាដូចជាសត្វល្អិត និងជម្ងឺផ្សិតជាដើម ។

## <u>ការសាងសង់ជង្រុក ឬ បរិក្ខារទុកដាក់ជាគំនរ</u>

អាស្រ័យទៅតាមប្រាក់កាសដែលកសិករមានសម្រាប់ចំណាយ បរិមាណគ្រាប់ស្រូវដែលត្រូវទុកដាក់រយៈពេល ដែលត្រូវទុកដាក់ និង សម្ភារៈសាងសង់ដែលអាចរកបាន ជង្រុក ឬ បរិក្ខារទុកដាក់ (រូបទី ១១ និង ១២) អាចនឹងត្រូវបានសាងសង់ដោយប្រើប្រាស់សម្ភារៈសំណង់ដែលមានលក្ខណៈសមស្រប ដូចជា ៖

- ដើម ឬ រនាប ឬស្សី
- កូនឈើ
- ឈើអារថ្មី ឬ ឈើដែលធ្លាប់ប្រើរួចហើយ
- ស្លឹកកណ្តប ស្បូវ ឬ សម្ភារៈស្រដៀងគ្នា
- ហ្វីប្រូស៊ីម៉ងត៍ និង
- សំណាញ់ដែក បើអាចរកបាន ។

ដោយសារថាស័ង្កសី បន្ទះដែក និង សំពត់កៅស៊ូ ពុំមានភាពសមស្របសម្រាប់លក្ខខណ្ឌអាកាសធាតុ ហើយច្រើនបង្កអោយមានបញ្ហាកំណញើស គួរតែប្រើវាធ្វើជាជញ្ជាំងខាងក្រៅ ឬ គ្រាន់តែបាំងដើម្បីការពារទឹកភ្លៀង ជាពិសេសនៅពេលដែលជញ្ជាំងជង្រុកធ្វើអំពីរនាបឬស្សី ឬ សំណាញ់ដែក ។



*រូបទី ១១. ជង្រុកដែលល្អត្រឹមត្រូវមួយ ៖ អាចបាំងទប់សំណើម សត្វកណ្ដុរ និង សត្វស្លាប ព្រមទាំងធ្វើអោយមានខ្យល់បក់ឆ្លងកាត់ (ប្រភព AQIP)*



*រូបទី ១២. ជង្រុកដែលល្អមួយបែបទៀត*

*(សូមពិនិត្យមើលរបាំងការពារកណ្ដុរនៅចន្លោះបង្គោលសសរ និង បាតជង្រុក)*

ដើម្បីអោយមានខ្យល់បក់ចេញចូលគ្រប់គ្រាន់ ហើយអាចការពារបានជាមួយនឹងសត្វកណ្ដុរ និង សត្វស្លាប ជញ្ជាំងជង្រុកអាចនឹងត្រូវសាង់សង់ដោយប្រើប្រាស់សំណាញ់ដែក (រូបទី ១៣) ឬ គ្រឿងសំណង់ដែលអាចរកបានក្នុងភូមិដូចជារនាប ឬ ប្រដឹសឫស្សី ឬ កូនឈើជាដើម ។



*រូបទី ១៣. ជញ្ជាំងជង្រុកធ្វើអំពីសំណាញ់ដែកដើម្បីអោយមានខ្យល់បក់ឆ្លងកាត់គ្រប់គ្រាន់ និង ដើម្បីការពារទប់មិនអោយសត្វកណ្ដុរ និង សត្វស្លាបអាចចូលបាន*

*ទីតាំងសំណង់*

ភ្នាក់ងារផ្សព្វផ្សាយគួរតែណែនាំកសិករអោយជ្រើសរើសទីតាំងសង់ជង្រុកនៅក្បែរផ្ទះ ដើម្បីងាយស្រួលអនុវត្ត កិច្ចការទុកដាក់ ចេញចូល ថែរក្សា និង ការពារកុំអោយគេលួច ។ ទីតាំងនោះគួរតែខ្ពស់ដែលពុំធ្វើអោយមានទឹកដក់ មានដីរឹង និង មានច្រកចេញចូលទៅដល់ផ្លូវដែលអាចសម្រួលដល់ការដឹកជញ្ជូន ។

*ទំហំ*

ជង្រុកអាចមានរាងមូល ឬ បួនជ្រុង ធំ ឬ តូច អាស្រ័យទៅតាមការជ្រើសរើសរបស់កសិករ កម្លាំងពលកម្មដែលមាន និង បរិមាណគ្រាប់ស្រូវដែលត្រូវទុកដាក់ ។ ជាឧទាហរណ៍ ជង្រុកដែលមានទំហំ ២ × ២.៥ × ២.៥ ម៉ែត្រ (ទទឹង × បណ្តោយ × កំពស់ស្លាបជញ្ជាំង) អាចទុកដាក់បានស្រូវប្រមាណជា ៣ ទៅ ៤ តោន ។

បាតក្រោមរបស់ជង្រុក គួរលើកអោយខ្ពស់ផុតពីដីប្រមាណជា ៦ តឹក ទៅ ១ ម៉ែត្រ ដើម្បីការពារមិនអោយសំណើមពីដីឆ្លងចូលទៅស្រូវ និង ដើម្បីអោយមានខ្យល់បក់ឆ្លងកាត់បានខ្លះ ។ គួរធ្វើធ្វើអោយមានប្រឡោះ ដែលមានសន្ទះរុញបិទបើកនៅនឹងបាតជង្រុកត្រង់កន្លែងណាមួយដើម្បីងាយស្រួលបង្ហូរយកស្រូវចេញ ។

__លក្ខណៈ និង ការធ្វើអោយមានខ្យល់បក់ឆ្លងកាត់__

ការសាងសង់ជង្រុក ឬ កន្លែងទុកដាក់នៅក្រោមផ្ទះ ក្រោមដើមឈើ ដោយដាក់អោយវាមានបណ្តោយតាម ទិសលិច-កើត អាចជួយកាត់បន្ថយកំដៅដែលបង្កឡើងដោយព្រះអាទិត្យ ។ សំយាបដំបូលដែលលយចេញពីជញ្ជាំងយ៉ាងតិច ១ ម៉ែត្រ អាចផ្តល់ជាម្លប់ដល់ជង្រុក ឬ កន្លែងទុកដាក់ ហើយអាចជួយការពារទឹកភ្លៀងមិនអោយសាចដល់ជញ្ជាំង ។

ការដាក់អោយជង្រុកប្រឈមជាមួយទិសខ្យល់បក់ធ្វើអោយកើតមានតុល្យភាពកំដៅ និង ខ្យល់បក់ឆ្លងកាត់បានស្មើល្អ ដែលអាចជួយកាត់បន្ថយនូវការយាយីបំផ្លាញពីសំណាក់សត្វល្អិតចង្រៃ និង កំណជាញើស។ រួមជាមួយនឹងការធ្វើអនាម័យសម្អាតជាប្រចាំ ការធ្វើអោយមានខ្យល់បក់ឆ្លងកាត់គ្រប់គ្រាន់អាចជួយរក្សាគុណភាពគ្រាប់ស្រូវអោយនៅខ្ពស់ល្អដោយមិនចាំបាច់ប្រើប្រាស់ថ្នាំពុល ឬ សារធាតុគីមីផ្សេងៗ ។ ការបិទបាំងប្រឡោះជញ្ជាំងនៅក្រោមដំបូល (ដោយប្រើប្រាស់រនាបឬស្សី ឬ សំណាញ់ដែក) អាចទប់ស្កាត់មិនអោយសត្វស្លាបចេញចូលបាន ។

កសិករអាចធ្វើពិដាននៅក្រោមដំបូល (ជាឧទាហរណ៍ នៅពេលដែលដំបូលត្រូវបានសាងសង់ឡើងដោយដែក ស័ង្កសី) ដើម្បីកាត់បន្ថយឥទ្ធិពលនៃកំដៅព្រះអាទិត្យ ប៉ុន្តែ ពិដានអាចក្លាយជាជម្រកដ៏ល្អរបស់សត្វចង្រៃនានា ហើយមានពេលខ្លះអាចបង្កអោយមានការលំបាកក្នុងការសម្អាត ។

ប្រសិនបើអាចមានភ្លៀងក្នុងអំឡុងពេលទុកដាក់ គួរបាំងជង្រុកដោយសំពត់កៅស៊ូ (ប៉ុន្តែត្រូវជៀសវាងការគ្របបាំងរហូត ជាពិសេសនៅពេលដែលស្រូវមានអត្រាសំណើមខ្ពស់ជាង ១៣ %)

## ការដាក់ស្រូវចូល

ដើម្បីកាត់បន្ថយនូវការខូចខាត ឬ ការបាត់បង់ដែលបង្កឡើងដោយកំដៅ សំណើម និង សត្វល្អិត ភ្នាក់ងារផ្សព្វផ្សាយគួរណែនាំកសិករអោយអនុវត្តនូវវិធីទាំងឡាយខាងក្រោម ៖

- សម្អាតរាល់សម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ទាំងអស់អោយបានស្អាតនៅមុនពេលប្រមូលផល
- បិទភ្ជិតកន្លែងទុកដាក់ ហើយដាក់អោយមានរបាំងទប់សត្វចង្រៃ
- ធ្វើអោយបានប្រាកដថាគ្រាប់ស្រូវត្រូវបានហាលសម្ងួត និង ស្អាតគ្រប់គ្រាន់មុននឹងយកទៅទុកដាក់
- ទុកដាក់ស្រូវថ្មីដោយឡែកពីស្រូវចាស់ ឬ ស្រូវល្អផ្សេងពីស្រូវដែលបានរងការបំផ្លាញ
- ទប់ស្កាត់ការឆ្លងនៃសត្វចង្រៃពីជង្រុក កន្លែងទុកដាក់ ពីសម្រាម ឬ ទីកខ្វក់ដែលនៅក្បែរខាង
- បំបាត់ចេញនូវអ្វីៗដែលអាចជាជម្រកនៃសត្វចង្រៃដូចជារន្ធ ឬ ស្នាមប្រេះផ្សេងៗ (ដោយបិទភ្ជិត)
- ជួសជុលកន្លែងដែលបាក់បែក ឬ ខូចខាតជាបន្ទាន់
- សម្អាតជង្រុក ឬ កន្លែងទុកដាក់ និង បរិវេណជុំវិញអោយបានស្អាតជាប្រចាំ និង
- រក្សាអោយកំដៅ (សីតុណ្ហភាព) និង សំណើមនៅក្នុងជង្រុក ឬ កន្លែងទុកដាក់ មានកម្រិតទាបបំផុតតាមដែលអាចធ្វើបាន ។ កសិករគួរស៊កបំពង់ឫស្សី ឬ បំពង់ទីក ឬ បំពង់ធ្វើអំពីសំណាញ់ដែកដែលមានរន្ធចំហៀងយ៉ាងច្រើនគ្រប់គ្រាន់ ចូលទៅក្នុងគំនរស្រូវពីលើចុះក្រោមដើម្បីអោយខ្យល់ក្តៅដែលនៅផ្នែកខាងក្រោម ឬ ខាងក្នុងនៃគំនរអាចរសាត់ចេញទៅក្រៅតាមមាត់បំពង់បាន ។

គួរពិនិត្យមើលជង្រុក ឬ កន្លែងទុកដាក់ និង ស្រូវអោយបានជាប្រចាំ (យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍) ក្រែងមានសត្វល្អិត ឬ បញ្ហានានាដែលបង្កអោយប៉ះពាល់ដល់គុណភាព ។ ប្រសិនបើសង្កេតឃើញថាមាន "ចំណុចក្តៅ" គួរតែធ្វើវាអោយចុះត្រជាក់ភ្លាមតាមដែលអាចធ្វើបាន ដោយធ្វើអោយមានខ្យល់បក់ឆ្លងកាត់ ។ ក្នុងករណីដែលសង្កេតឃើញមានការយាយីបំផ្លាញពីសំណាក់សត្វល្អិត ជំនួសអោយការប្រើប្រាស់ថ្នាំពុល ឬ សារធាតុគីមីផ្សេងៗ កសិករអាចនឹងកំចាត់វាបានដោយវិធីជីវសាស្ត្រ និង វិធានការណ៍ចម្រុះ ។ ជាមួយវិធីទាំងនោះកសិករគ្រាន់តែប្រើសត្រូវធម្មជាតិ (ដូចជាសារធាតុធម្មជាតិដែលពួកវាមិនចូលចិត្ត ឬ ទ្រាំទ្រជាមួយមិនបាន សត្វដែលស៊ីពួកវាជាអាហារ និង ប៉ារ៉ាស៊ីតផ្សេងៗ) ក៏ដូចជាអង្កប់ ឬ ជ្រើសរើសពូជស្រូវដែលមិនងាយ ឬ មិនសូវរងការបំផ្លាញ ។ វិធីផ្សេងទៀតមាន ៖

- ការចាក់ស្រូវហាលក្រោមកំដៅថ្ងៃ
- ការដាក់អោយស្រូវ ឬ ជង្រុក ឬ កន្លែងទុកដាក់រងផ្សែងពីផ្ទះបាយ
- ការបំពក់អោយមានផ្សែងដែលដុតដោយប្រើម្ទេស ឬ ម្រេចហឹរអាចដេញសត្វល្អិតចេញពីស្រូវបានយ៉ាងឆាប់រហ័ស ប៉ុន្តែវាអាចធ្វើអោយប៉ះពាល់ដល់រសជាតិស្រូវអង្ករ ឬ បាយ ។

កសិករអាចយកសារធាតុផ្សេងទៀតដែលសម្លាប់ ឬ បន្ថយល្បឿនធ្វើចលនានៃសត្វល្អិតទៅដាក់ក្នុងស្រូវដូច ជាផេះ ធូលីទប់ចលនា (ធូលីដីក្រួសក្រហម ធូលីដីឥដ្ឋ ឬ កំបោរ ។ល។) និង ដីខ្សាច់គ្រាប់តូច ។ ដោយសារ

ថាតម្រូវការនៃសារធាតុទាំងនេះអាចមានច្រើន វាអាចនឹងត្រូវប្រើបានតែសម្រាប់បរិមាណស្រូវតិចតួច (ដូចជាការទុកដាក់ពូជ) តែប៉ុណ្ណោះ ។

គួរជៀសវាងកុំប្រើសារធាតុរុក្ខជាតិដែលមានជាតិពុល ឬ លឹង្គខ្លាំងជាមួយស្រូវដែលទុកសម្រាប់ការហូបចុករបស់មនុស្ស សត្វ ។ ទោះជាបែបនេះក្តី សារធាតុទាំងនោះអាចមានប្រសិទ្ធិភាពយ៉ាងខ្ពស់ក្នុងការរក្សាទុកស្រូវពូជ ។

លាមកសត្វពុំមានប្រសិទ្ធិភាព និង អនាម័យទេ ហេតុនេះគួរកុំប្រើប្រាស់វាដើម្បីការពារជង្រុក ឬ ស្រូវ ។

## ២.៤.២ ការទុកដាក់ក្នុងបាវ

ការទុកដាក់ស្រូវក្នុងបាវធ្វើអំពីក្រចៅ ឬ សរសៃនីឡុងជាគំនរជាវិធីដែលធ្វើអោយចំណាយតិច (បាវមួយអាចមានតម្លៃពី ៥០០ ទៅ ១០០០ រៀល) មានភាពងាយស្រួលក្នុងការអនុវត្តន៍ និង គ្រប់គ្រង ។ ប៉ុន្តែនៅក្រោម លក្ខខណ្ឌអាកាសធាតុដ៏អាក្រក់ខ្លាំង អត្រាសំណើមនៃគ្រាប់ស្រូវនៅក្នុងបាវទាំងនោះអាចនឹងប្រែប្រួលឡើងចុះដោយសារថាសំណើមបរិយាកាសអាចជ្រៀតចូលទៅក្នុងស្រូវបាន ។ កំដៅរួមទាំងសំណើមបរិយាកាសខ្ពស់ នឹងធ្វើអោយគ្រាប់ស្រូវដែលនៅក្នុងបាវរងការយាយីបំផ្លាញពីសំណាក់សត្វល្អិត ទោះបីជាគ្រាប់ស្រូវនោះត្រូវបានសម្ងួតអោយស្ងួតគ្រប់គ្រាន់នៅមុនពេលទុកដាក់ហើយក៏ដោយ ។

***អនុសាសន៍មួយចំនួន ៖***

- រៀបបាវស្រូវអោយឃ្លាតពីជញ្ជាំង នៅលើក្តារទម្រ ឬ កំណល់ផ្សេងៗដែលមានលក្ខណៈប្រហាក់ប្រហែល ធ្វើយ៉ាងណាអោយមានប្រឡោះគ្រប់គ្រាន់ដើម្បីអោយខ្យល់បក់ឆ្លងកាត់ (រូបទី ១៤)
- ក្តារ ឬ កំណល់ទម្រគួរមានកំពស់ប្រមាណជា ១ តឹក ពីដី ឬ ពីបាតជង្រុកដើម្បីអោយខ្យល់អាចបក់កាត់ពីក្រោមគំនរបាវ ។ ធ្វើរបៀបនេះ ក៏បង្កអោយមានភាពងាយស្រួលក្នុងការត្រួតពិនិត្យមើលក្រែងមានការបំផ្លាញពីសត្វកណ្តុរផងដែរ
- ដើម្បីកុំអោយវាងាយដួលរលំ គួររៀបគំនររបាវស្រូវអោយបានត្រឹមត្រូវ (រូបទី ១៥) ដោយជៀសវាងកុំអោយវាមានកំពស់ខ្ពស់ជាង ៤ ម៉ែត្រ ។ ត្រូវដឹងថា បាវ ឬ ថង់ប្លាស្ទិកមានភាពរអិល ងាយធ្វើអោយគំនរងាយដួលរលំជាងបាវក្រចៅ ។




***រូបទី ១៤ ការរៀបគំនរបាវត្រឹមត្រូវ និង មិនត្រឹមត្រូវ***




*រូបទី ១៥ ការរៀបបាវជាជុង*



*រូបទី ១៦ ឃ្លាំងសមស្របមួយដែលមានច្រកសម្រាប់ខ្យល់ត្រជាក់ចូលពីខាងក្រោម និង សម្រាប់ខ្យល់ក្តៅចេញខាងលើ (ច្រកទាំងនោះត្រូវបានពាសដោយសំណាញ់ដើម្បីការពារកណ្តុរ និង សត្វស្លាប)*

### ២.៤.៣ ការទុកដាក់ក្នុងបរិក្ខារបិទជិត

ការទុកដាក់ក្នុងបរិក្ខារបិទជិតមិនអោយខ្យល់អាចជ្រៀតចេញចូលបាន អាចជាការទប់ស្កាត់ដ៏ល្អចំពោះសត្វចង្រៃ និង សំណើម ដោយមិនប្រើប្រាស់សារធាតុគីមី ។

ការទុកដាក់បិទជិតធ្វើអោយថយចុះនូវកម្រិតអុកស៊ីហ្សែនដែលគ្រាប់ស្រូវ សត្វល្អិត និង ផ្សិតត្រូវការសម្រាប់ការដកដង្ហើម និង លួតលាស់ហើយផ្តុយទៅវិញវាបង្កើនកម្រិតឧស្ម័នកាបូនិក ។ អុកស៊ីហ្សែនដែលនៅសល់ក្នុងបរិក្ខារប្រភេទនេះ មានកម្រិតគ្រប់គ្រាន់សម្រាប់តែរក្សាបាននូវសមត្ថភាពដំណុះរបស់គ្រាប់ពូជ ប៉ុន្តែមិនអាចអោយសត្វល្អិតអាចនៅរស់ ឬ ធ្វើការបន្តពូជបានឡើយ ។ ហេតុនេះ ការភ្ជិតអោយបានជិតត្រឹមត្រូវមានសារៈសំខាន់ណាស់ ។ ប្រសិនបើកសិករហាលសម្ងួតគ្រាប់ស្រូវអោយមានអត្រាសំណើម ១៤ % ឬ ទាបជាងនេះ គ្រាប់ស្រូវដែលទុកដាក់ដោយវិធីនេះអាចមានសុវត្ថិភាពក្នុងរយៈពេលយូរជាង ១ ឆ្នាំ ។





ថង់បិទជិតចំណុះ ៧០០ ទៅ ១៣០០ លីត្រ





Cocoon ឬ Volcani cube ដែលផ្ទុក

***រូបទី ១៧ បរិក្ខារបិទជិតមួយចំនួន***

បរិក្ខារសម្រាប់ការទុកដាក់បិទជិតមានរូបរាង និង ទំហំខុសៗគ្នា (រូបទី ១៧) ។ វាអាចជាធុងប្រេងដែលគេ ប្រើហើយចំណុះពី ២០ ទៅ ២០០ លីត្រ រហូតដល់ជាធុង ឬ បរិក្ខារប្លាស្ទិកដែលមានសណ្ឋានសាំញ៉ាំ និងតម្លៃខ្ពស់ដែលត្រូវបានគេផលិតលក់ ។ ប្លាស្ទិកប្រភេទផ្សេងៗអាចទប់ចំពោះការជ្រៀតនៃខ្យល់ និង សំណើមបាន ក្នុងកម្រិតខុសៗគ្នា ។ ក្រឡកែវ ធុងជ័រ PVC និង ថង់ដែលមានស្រទាប់អាលុយមីញ៉ូមអាចទប់ស្កាត់បានយ៉ាងល្អនូវការជ្រៀតសំណើម ។ គេក៏អាចតម្រៀបបាវស្រូវធម្មតានៅក្នុងបរិក្ខារបិទជិតមួយចំនួនបានដែរ ។

តម្លៃរបស់ប្រព័ន្ធទុកដាក់ប្រភេទនេះប្រែប្រួលទៅតាមតម្លៃធុង ឬ ប្រអប់ផ្សេងៗដែលគេប្រើហើយ (ឧទា ហរណ៍ ធុងសាំងចំណុះ ២០០ លីត្រអាចមានតម្លៃប្រមាណជា ៨ ពាន់ ទៅ ២ ម៉ឺនរៀល) ។ ប្រព័ន្ធទុកដាក់បែបពាណិជ្ជកម្មមានតម្លៃដើម (ថ្លៃទិញ) ពី ២០ ទៅ ៤០ ម៉ឺនរៀលសម្រាប់ស្រូវ ១ តោន ។ ជាមួយនឹងអាយុកាលប្រើប្រាស់ប្រមាណជា ១០ ឆ្នាំ មានន័យថាវាមានតម្លៃប្រមាណជា ២ ទៅ ៤ ម៉ឺនរៀល សម្រាប់ការទុកដាក់ស្រូវ ១ តោន ក្នុងរយពេល ១ ឆ្នាំ ។

ថង់ Super របស់ IRRI ត្រូវបានគេផលិតឡើងដើម្បីអោយអាចច្រកស្រូវបានប្រមាណជា ៥០ គីឡូក្រាម ។ គេអាចផលិតវាអោយមានទំហំតូច ឬ ធំជាងនេះធ្វើជាថង់ច្រកផ្ទាល់ ឬ ដើម្បីដាក់ទ្រាប់ពីក្នុងបាវធម្មតា ។ គេអាចនឹងប្រើវាបានឡើងវិញប្រសិនបើវាពុំមានដាច់ធ្លុះធ្លាយ ឬ រហែក ។ រូបទី ១៨ បង្ហាញពីវិធីទុកដាក់ស្រូវក្នុងបាវនេះ ដែលដាក់ជាទ្រនាប់ពីក្នុងបាវប្លាស្ទិកធម្មតា ។



*១. ដាក់ថង់ Super bag ជាទ្រនាប់ពីក្នុងថង់ធម្មតា*



*២. ច្រកគ្រាប់ស្រូវដែលស្ងួតចូល*

*៣. បន្សាត់ខ្យល់ចេញ ហើយមួលមាត់ថង់*



*៤. បត់ផ្គួបមាត់ថង់ ហើយចងវាដោយកៅស៊ូក្រាស់ ឬ ស្កុត*

***រូបទី ១៨ វិធីច្រកស្រូវទុកក្នុងថង់ Super bag***

ក្រឡផ្ទៃពីដីឥដ្ឋក៏អាចប្រើជាបរិក្ខារបិទជិតបានដែរ ។ ដើម្បីកុំអោយសំណើម និង សត្វល្អិតអាចជ្រៀតចូលបានត្រូវគ្របវាអោយជិត ហើយលាបថ្នាំអោយរលោងទាំងក្នុងទាំងក្រៅ ។ ដើម្បីធ្វើអោយប្រាកដថា បរិក្ខារនេះមានភាពជិតល្អ គេអាចយកក្រមួន ខ្លាញ់គោ ឬ កាវស៊ីលីកុងទៅលាបនៅមាត់ក្រឡនោះមុនពេលគ្របភ្ជិត ។ ការយកក្រណាត់ទៅជ្រលក់ជាមួយក្រមួនក្តៅ ហើយយកទៅរុំលើមាត់ក្រឡ ក៏ជាមធ្យោបាយជួយបិទក្រឡអោយជិតបានដែរ ។

ការប្រុងប្រយ័ត្នជាពិសេសត្រូវតែមានជាមួយនឹងការប្រើប្រាស់បរិក្ខារ ឬ ប្រព័ន្ធបែបនេះ ៖

- ត្រូវលាងសម្អាតអោយបានស្អាតនូវធុង ឬ ប្រអប់ទាំងឡាយមុននឹងយកវាទៅប្រើប្រាស់
- ត្រូវដាក់កុំអោយបរិក្ខារទាំងនោះត្រូវ ឬ រងកំដៅថ្ងៃ ឬ ប្រភពកំដៅអ្វីផ្សេងទៀត ដើម្បីជៀសវាងការកើតមានកំណញើស ។ សំណើមអាចមានចលនាពីក្រោមឡើងទៅលើនៅក្នុងបរិក្ខារធំៗ ប្រសិនបើបរិក្ខារនោះមិនត្រូវបានដាក់ក្នុងម្លប់ ។ ពុំមានសម្បកបាវ ធុង ឬ ប្រអប់ណាដែលអាចការពារគ្រាប់ស្រូវពីឥទ្ធិពលរបស់កំដៅបានឡើយ ។ សម្រាប់ការកើនឡើងនូវសីតុណ្ហភាព ៥ អង្សារសេជីវិតរបស់គ្រាប់ពូជស្រូវអាចនឹងត្រូវកាត់បន្ថយអោយចុះអស់ពាក់កណ្តាល
- គួរជៀសវាងការបើកបិទធុង ឬ បរិក្ខារទុកដាក់ ។ ការបើកបិទអាចបណ្តាលអោយអុកស៊ីហ្សែនជ្រៀតចូលទៅក្នុងបរិក្ខារបាន ។ សត្វល្អិតមួយចំនួនអាចចោះទំលុះស្រទាប់ស្បោង ប្លាស្ទិកបាន
- ប្រសិនបើស្រូវមិនត្រូវបានចាក់អោយពេញបរិក្ខារ ខ្យល់ដែលនៅផ្នែកខាងលើអាចមានច្រើនគ្រប់គ្រាន់សម្រាប់ការដកដង្ហើមរបស់សត្វល្អិត
- បរិក្ខារទុកដាក់ធុនធំដែលគេផលិតលក់ក្នុងលក្ខណៈពាណិជ្ជកម្ម (ដូចជា Volcani cube ជាដើម) អាចកាត់បំផ្លាញបានដោយកណ្តុរ ។ ហេតុនេះ ត្រូវទាញសន្ធឹងវាអោយតឹង ហើយលៃលកអោយមានប្រឡោះទំនេរនៅជុំវិញវាប្រមាណជាកន្លះម៉ែត្រ ។

## ២.៥ ផលចំណេញអំពីការកែលម្អ

ការទទួលយកទៅអនុវត្តនូវបរិក្ខារដែលបានកែលម្អ និង វិធានការណ៍ទប់ស្កាត់ផ្សេងៗសម្រាប់ការទុកដាក់ស្រូវជាគំនរក្នុងបាវ និង នៅក្នុងបរិក្ខារបិទជិតអាចផ្តល់នូវផលចំណេញដល់កសិករ ។

ការវិភាគជារួមដ៏សាមញ្ញមួយ ដែលបង្ហាញអោយឃើញនូវផលចំណេញអំពីការទទួលយកទៅអនុវត្តនូវបច្ចេកទេសដូចដែលបានរៀបរាប់មកនេះ សម្រាប់រយៈពេល ៥ ឆ្នាំ មាននៅក្នុងតារាងខាងក្រោម ។ ការវិភាគនេះបានផ្អែកទៅលើការសន្មត់មួយចំនួនដូចតទៅ ៖

- គ្រាប់ស្រូវពូជផ្កាម្លិះត្រូវបានផលិតដោយកសិករផ្ទាល់ មានន័យថាគាត់ពុំចំណាយប្រាក់ដើម្បីទិញវា
- មានបរិមាណស្រូវចំនួន ៣ តោនសម្រាប់ទុកដាក់រៀងរាល់ឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំ

- ការបាត់បង់បរិមាណមានប្រមាណជា ៥ % (គឺថាគាត់នៅសល់ ៣000 គីឡូក្រាម/ឆ្នាំ ៥ ឆ្នាំ ៩៥% = ១៤២៥0 គីឡូក្រាម ) ជាមួយនិងការទុកដាក់តាមទម្លាប់ (ដោយដាក់ក្នុងជង្រុក ឬ ច្រកបាវហើយពុំមានវិធានការណ៍ទប់ស្កាត់អ្វីទាំងអស់) និង 0 % ជាមួយនិងការអនុវត្តន៏បច្ចេកទេសថ្មី
- ស្រូវទាំងអស់ត្រូវបានលក់យកប្រាក់នៅក្រោយពេលទុកដាក់
- ដោយសារថាស្រូវដែលទុកដាក់តាមវិធីថ្មីមានគុណភាពខ្ពស់ជាង វាអាចលក់បានក្នុងតម្លៃ ៨៥0 រៀល/គីឡូក្រាម គឺ ១00 រៀល ថ្លៃជាងស្រូវដែលបានទុកដាក់តាមទម្លាប់ធម្មតា (៧៥0 រៀល សម្រាប់ពូជនេះ លក់នៅខេត្តបាត់ដំបងក្នុងខែវិច្ឆិកា ឆ្នាំ ២00៦)
- ជាមួយនិងការទុកដាក់តាមទម្លាប់ កសិករចំណាយដើមទុនតិចតួចដើម្បីសាងសង់ ឬ អាចប្រើប្រាស់សំណង់ ឬ បរិក្ខារដែលគាត់មានស្រាប់ ប៉ុន្តែគាត់បែរជាចំណាយអស់ប្រាក់ច្រើនដើម្បីទិញបរិក្ខារ (ដូចជាសម្បកបាវជាដើម) មកជំនួសអោយការខូចខាតដែលបណ្តាលមកពីកត្តាចង្រៃនានា
- ជាមួយនិងវិធីថ្មី កសិករចំណាយអស់ប្រាក់ដើមប្រមាណជា ៤២ ម៉ឺនរៀល ដើម្បីកែលម្អជង្រុកដែលគាត់មានស្រាប់ ឬ ក៏ដើម្បីទិញបរិក្ខារ ឬ របស់របរសម្រាប់ប្រើក្នុងការទុកដាក់ផ្សេងទៀត (ដូចជាទិញធុង ថង់ ឬ បរិក្ខារបិទជិត) ហើយចំណាយអស់ប្រាក់តិចជាងធម្មតាដើម្បីទិញ ឬ ជួសជុលបរិក្ខារដែលខូច ត្បិតវិធានការការពារនានាត្រូវបានប្រកាន់យក
- ការទុកដាក់តាមទម្លាប់ត្រូវការចំណាយប្រាក់អស់ ៣៥000 រៀល ដើម្បីថែរក្សា និង ជួសជុលប្រចាំឆ្នាំ ឯការទុកដាក់តាមវិធីថ្មីត្រូវការប្រាក់ ២0000 រៀល
- ជង្រុកស្រូវថ្មីអាចប្រើប្រាស់បាន ៥ ឆ្នាំ ដោយតម្រូវអោយមានការជួសជុលតិចតួច
- ជាមួយនឹងវិធីសាស្ត្រថ្មី កសិករត្រូវចំណាយពេលវេលា និង កម្លាំងពលកម្មច្រើនដើម្បីសាងសង់ និង អនុវត្តវិធានការផ្សេងៗ ។

*ការវិភាគសេដ្ឋកិច្ចលើការទុកដាក់តាមទម្លាប់ និង តាមវិធីសាស្ត្រថ្មី ក្នុងរយៈពេល ៥ ឆ្នាំ*

| **បរិយាយ** | **ជាមួយការទុកដាក់តាមទម្លាប់** | | | **ជាមួយវិធីសាស្ត្រថ្មី** | | |
|---|---|---|---|---|---|---|
| **ចំណូល** | **បរិមាណ** | **ថ្លៃឯកតា** | **ថ្លៃសរុប** | **បរិមាណ** | **ថ្លៃឯកតា** | **ថ្លៃសរុប** |
| | គីឡូក្រាម | រៀល/គីឡូ | ពាន់រៀល | គីឡូក្រាម | រៀល/គីឡូ | ពាន់រៀល |
| ពីការលក់ស្រូវ | 14250 | 750 | 10687,5 | 15000 | 850 | 12750 |
| | | | | | | |
| | **បរិមាណ** | **ថ្លៃឯកតា** | **ថ្លៃសរុប** | **បរិមាណ** | **ថ្លៃឯកតា** | **ថ្លៃសរុប** |
| **ការចំណាយជាប្រាក់** | ឆ្នាំ | ពាន់រៀល/ឆ្នាំ | ពាន់រៀល | ឆ្នាំ | ពាន់រៀល/ឆ្នាំ | ពាន់រៀល |
| សាងសង់ និង សម្ភារៈ | 5 | 30 | 150 | 5 | | 300 |
| ការជំនួសបរិក្ខារខ្លះ | 5 | 30 | 150 | 5 | 15 | 75 |
| សម្ភារៈការពារកត្តាចង្រៃ | 5 | 5 | 25 | 5 | 5 | 25 |
| កម្លាំងពលកម្ម8 | | | | 20 នាក់.ថ្ងៃ | 6000 រៀល | 120 |
| សរុបប្រាក់ចំណាយ | | | 325 | | | 520 |
| ប្រាក់នៅសល់/៥ ឆ្នាំ | | | 10362,5 | | | 12230 |
| ប្រាក់នៅសល់,ឆ្នាំ | | | 2072,5 | | | 2446 |
| ប្រាក់ចំណូលកើនឡើងដោយការអនុវត្តន៍បច្ចេកទេសថ្មី,ឆ្នាំ | | | | | | 373,5 |

* *កម្លាំងពលកម្មដែលកសិករត្រូវចំណាយបន្ថែម ឬច្រើនជាងមុនដើម្បីអនុវត្តនូវវិធីថ្មី*

ដូចដែលបានឃើញរួចមកហើយ ការទទួលយកទៅអនុវត្តនូវវិធីទុកដាក់ថ្មី មានប្រសិទ្ធិភាពសេដ្ឋកិច្ចសម្រាប់រយៈពេលវែង ។ ក្នុងរយៈពេលអនុវត្តន៍វិធីថ្មី ៥ ឆ្នាំ កសិករដែលមានស្រូវទុកដាក់ ៣ តោនក្នុងមួយឆ្នាំ អាចរក ឬសន្សំបានប្រាក់ប្រមាណជា ៣៧ ម៉ឺនរៀល ច្រើនជាងធម្មតា ។

ដោយឡែកពីផលចំណេញខាងលើនេះ ផលចំណេញដោយផ្ទាល់ដែលកសិករអាចនឹងទទួលបានផងដែរ ជាមួយនឹងការទទួលទៅអនុវត្តន៍នូវវិធីសាស្ត្រថ្មី រួមមាន ៖

- គ្រាប់ស្រូវនៅរក្សាបានពណ៌សម្បុរ និង ក្លិនល្អដដែល ដែលបញ្ជាក់ថាវាពុំបានទទួលរងនូវការខូចខាតដោយសារសំណើម កំដៅ និង សកម្មភាពបំផ្លាញផ្សេងទៀត
- ដោយឡែកពីការស្រកចុះទម្ងន់ដែលបណ្តាលមកពីការស្រកចុះនូវអត្រាសំណើម អាចកើតមាននូវការបាត់បង់បរិមាណតិចតួចប៉ុណ្ណោះ
- គ្រាប់ពូជស្រូវអាចនៅមានអត្រាដំណុះខ្ពស់ជាង ៨0 % ទោះបីជាទុកដាក់បាន ១ ឆ្នាំ ហើយក៏ដោយ ដែលនេះបានសេចក្តីថាកសិករអាចប្រើប្រាស់គ្រាប់ពូជអស់តិចជាងធម្មតា (មកត្រឹម ៤0 គីឡូក្រាម ក្នុងមួយហិកតា) ហើយ

- ក្លិន និង បរិស្ថានអាក្រក់ដែលបបង្កឡើងដោយសត្វចង្រៃ និង ជម្ងឺផ្សិត ដែលអាចធ្វើអោយមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស អាចនឹងត្រូវបានកាត់បន្ថយ ហើយដាក់អោយនៅដោយឡែកពីលំនៅដ្ឋាន ។

## ២.៦ ឥទ្ធិពលនៅលើបរិស្ថាន

ការប្រើប្រាស់នូវបរិក្ខារថ្មី ដោយរួមទាំងវិធានការការពារថ្មីនានា ប្រាកដជាអាចផ្តល់នូវផលល្អខាងផ្នែកបរិស្ថានមួយចំនួន ។ តាមរយៈឥទ្ធិពលរបស់វាក្នុងការកាត់បន្ថយ ឬ ទប់ស្កាត់នូវសកម្មភាពបំផ្លាញរបស់កត្តាចង្រៃនានា កសិករ និង មនុស្សទាំងឡាយដែលរស់នៅជិតខាងជង្រុក ឬ កន្លែងទុកដាក់ អាចទទួលបាននូវខ្យល់អាកាសបរិសុទ្ធ និង បរិយាកាសរស់នៅស្អាតបាត ព្រមទាំងមានអនាម័យច្រើនជាងធម្មតា ។ សំខាន់ជាងនោះទៅទៀត គ្រាប់ស្រូវអង្ករនឹងផ្តល់នូវសុវត្ថិភាពកាន់តែខ្ពស់ដល់ការហូបចុកទាំងរបស់មនុស្ស និង សត្វ ។

# ៣. គោលការណ៍ណែនាំក្នុងការផ្សព្វផ្សាយ

## ៣.១ ផែនការការងារ

### ៣.១.១ ការកំណត់តម្លៃដែលត្រូវចំណាយ

| សកម្មភាព | ឯកតា | បរិមាណ | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|
| កសាងផែនការសម្ភារៈ និង វិធីសាស្ត្រអនុវត្តន៍ | ថ្ងៃ | | | |
| កំណត់ទីកន្លែង និង ជ្រើសរើសកសិករចូលរួម8 | ថ្ងៃ | | | |
| រៀបចំ និង ចាត់ចែងរាល់សម្ភារៈបរិក្ខារដែលចាំបាច់ | ថ្ងៃ | | | |
| ធ្វើការអនុវត្តន៍បង្ហាញនៅពេលចាប់ផ្តើមទុកដាក់ | ថ្ងៃ | | | |
| ទិវាស្រែ (រៀងរាល់ ៣ ខែម្តង) | ថ្ងៃ | | | |
| ផ្សេងៗ | ថ្ងៃ | | | |
| សរុប | | | | |

** ចំនួនថ្ងៃប៉ាន់ស្មានដើម្បីអនុវត្តនូវការណែនាំក្នុងឯកសារនេះសម្រាប់កន្លែងមួយដែលមានកសិករចូលរួមពី ២០ ទៅ ២៥ នាក់*

### ៣.១.២ អ្នកគាំទ្រ

អ្នករៀបរៀងឯកសារ TIP នេះ កម្មវិធី CAAEP នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង ស្ថាប័ន ឬ អង្គការផ្សេងទៀតដែលកំពុងបំពេញការងារផ្នែកស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្ម អាចផ្តល់នូវការជួយគាំទ្រ ក្នុងករណីដែលត្រូវការឯកសារផ្សព្វផ្សាយ ការអនុវត្តន៍បង្ហាញ ឬ ការពន្យល់ ដែលមានលក្ខណៈលម្អិតជាងនេះ ។

### ៣.១.៣ យេនឌ័រ

កសិករ ឬ អ្នកគ្រប់គ្រងស្រូវភេទស្រីមានលក្ខណៈសមស្របនឹងទទួលបាននូវកិច្ចសហការ ដោយសារថាជាទូទៅគាត់គឺជាអ្នកគ្រប់គ្រងសកម្មភាពនានាដែលមានទំនាក់ទំនងដល់កិច្ចការផ្ទះសម្បែង ដោយរួមទាំងកិច្ចថែរក្សាបរិក្ខារសម្រាប់ទុកដាក់ស្រូវ និង គ្រាប់ស្រូវផង ។ ការអនុវត្តន៍ដោយជោគជ័យនូវឯកសារណែនាំនេះ អាចនឹងត្រូវធ្វើអោយបានសម្រេចដោយស្ត្រី និង បុរសដែលចូលរួមទាំងអស់ ហើយអាចស្តែងអោយឃើញជាក់ស្តែងតាមរយៈជីវភាព សុខភាព និង ប្រាក់ចំណូលកាន់តែខ្ពស់នៃអ្នកដែលចូលរួម និង របស់ក្រុមគ្រួសារគាត់ ។ ដោយសារតែមានការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនេះ ការចាត់ចែងអោយមានភ្នាក់ងារផ្សព្វផ្សាយ និង អនុវត្តន៍បង្ហាញភេទស្រីគួរតែត្រូវចាត់ទុកថាមានសារៈសំខាន់ ។

## ៣.២ វិធីសាស្ត្រផ្សព្វផ្សាយ

កសិករ និង អ្នកគ្រប់គ្រងស្រូវភាគច្រើន តែងទុកដាក់ស្រូវរបស់គាត់នៅជិត ឬ ក្បែរខាងផ្ទះ ។ អាស្រ័យហេតុនេះ វាជាការសំខាន់ដែលត្រូវចាត់ចែងអនុវត្តនូវកម្មវិធីផ្សព្វផ្សាយនេះនៅក្នុងភូមិជាមួយនឹងក្រុមកសិករដែលមានការចាប់អារម្មណ៍ ។

ដើម្បីអោយយល់បានកាន់តែច្បាស់ និង ដើម្បីបង្ហាញនូវប្រសិទ្ធិភាពនៃការទុកដាក់តាមវិធីផ្សេងៗទៅលើការបាត់បង់ និង គុណភាពអោយបានជាក់ស្តែង ត្រូវជ្រើសយកវិធីទុកដាក់អោយបាន ២ យ៉ាងតិចបំផុត។ លំដាប់ និង បែបបទដែលត្រូវប្រកាន់យកក្នុងការរៀបចំ អនុវត្តន៍ និង វាយតម្លៃកម្មវិធីផ្សព្វផ្សាយដែលបានអធិប្បាយក្នុងឯកសារនេះមានរៀបរាប់លម្អិតដូចតទៅ ៖

### ៣.២.១ ការជ្រើសរើសទីកន្លែង

ដោយសារថាបែបបទនេះមានភាពសមស្របសម្រាប់ស្ទើរតែគ្រប់តំបន់ក្នុងប្រទេសកម្ពុជា ពុំមានលក្ខណៈវិនិច្ឆ័យពិសេសណាសម្រាប់បញ្ជាក់ពីការជ្រើសរើសទីកន្លែងឡើយ ។ ប៉ុន្តែ វាជាការសំខាន់ដែលត្រូវជ្រើសរើសទីតាំងអនុវត្តន៍បង្ហាញនៅត្រង់កន្លែងណាដែលកសិករ ឬ អ្នកគ្រប់គ្រងស្រូវផ្សេងទៀតងាយស្រួលចេញចូលដើម្បីធ្វើការសង្កេត ។ ប្រសិនបើអាច ទីកន្លែងនោះគួរតែនៅក្បែរផ្លូវ ឬ ទីសាធារណៈ ដើម្បីអោយមានលក្ខណៈទាក់ទាញការចាប់អារម្មណ៍ពីមនុស្សទាំងឡាយដែលធ្វើដំណើរឆ្លងកាត់ ក្នុងន័យធ្វើអោយបច្ចេកវិទ្យា និង ការយល់ដឹងនេះអាចនឹងត្រូវបានចែករំលែក និង ពង្រាយបានសព្វ ឬ ច្រើនកន្លែង ។

### ៣.២.២ ការជ្រើសរើសកសិករ និង ការរៀបចំ

ដើម្បីកាត់បន្ថយនូវការចំណាយក្នុងការផ្សព្វផ្សាយ អោយមានប្រសិទ្ធិភាពខ្ពស់អំពីធនធានដែលបានប្រើប្រាស់ ភ្នាក់ងារផ្សព្វផ្សាយគួរ ៖

- ធ្វើការកត់សម្គាល់ និង ជ្រើសរើសកសិករ ឬ អ្នកគ្រប់គ្រងស្រូវ ដែលមានការចង់ដឹងចង់យល់ ចេះសហការ និង មានបទពិសោធន៍ ដើម្បីអនុវត្តកិច្ចការនេះរួមគ្នា ។ ដោយមានកិច្ចសហការពីគាត់ ភ្នាក់ងារផ្សព្វផ្សាយត្រូវតែគិតគូរជ្រើសរើសវិធីសាស្ត្រអនុវត្តន៍បង្ហាញ និង វិធីទុកដាក់ រៀបចំរាល់សម្ភារៈបរិក្ខារទាំងអស់ដែលត្រូវការ ចាត់ចែងអោយមានក្រុមអ្នកចូលរួម រហូតដល់ការសាងសង់ជង្រុក ឬ កន្លែងទុកដាក់ស្រូវ
- ផ្តល់ដល់កសិករ ឬ អ្នកគ្រប់គ្រង (ផ្ទះការ) ទាំងនោះនូវគ្រឿងលើកទឹកចិត្តខ្លះដើម្បីអោយគាត់មានគំនិតផ្តួចផ្តើម និង មានចិត្តចង់ចូលរួម ។ គ្រឿងលើកទឹកចិត្តនោះអាចជាប្រាក់កាសមួយចំនួនសម្រាប់ទិញ ឬ ជាវសម្ភារៈសំណង់ សម្ភារៈ ឬ បរិក្ខារទុកដាក់ដូចជាធុង ឬ ស្បោងបិទជិតនានាដូចដែលបានរៀបរាប់ពីខាងដើម ឬមួយជាស្រូវ ឬ អង្ករដែលបានប្រើប្រាស់ក្នុងវិធីទុកដាក់ទាំងឡាយនោះ និង
- អញ្ជើញ ឬ សហការជាមួយអាជ្ញាធរដែនដី និង អង្គការផ្សេងទៀតដែលកំពុងប្រត្តិបត្តិសកម្មភាពរបស់គេក្នុងទិសដៅ ឬ វិស័យប្រហាក់ប្រហែលគ្នានៅក្នុងតំបន់ ។

### ៣.២.៣ ការរួមចំណែកពីសំណាក់កសិករ និង អ្នកគ្រប់គ្រងការទុកដាក់ស្រូវ

កសិករ ឬ អ្នកគ្រប់គ្រងទាំងនោះគួរតែផ្តល់នូវទីតាំង និង គ្រាប់ស្រូវដែលត្រូវប្រើប្រាស់ ។

ជាបន្តទៅនេះ គឺជាវិធីសាស្ត្រធ្វើពិសោធន៍ ឬ ការអនុវត្តន៍បង្ហាញ ដែលភ្នាក់ងារផ្សព្វផ្សាយគួរធ្វើការស្វែងយល់ ដើម្បីអោយមានលទ្ធភាពអាចពន្យល់ និង បង្ហាញ ដើម្បីសម្រេចបាននូវប្រសិទ្ធិភាពខ្ពស់ក្នុងការអនុវត្តន៍បណ្តុះបណ្តាល ឬ សកម្មភាពផ្សព្វផ្សាយផ្សេងទៀត ។

## ៣.៣ ពិសោធន៍ និង ការអនុវត្តន៍បង្ហាញ

### ៣.៣.១ ចំណងជើង ការទុកដាក់ស្រូវ

### ៣.៣.២ ទីកន្លែង.............................................................................................................

### ៣.៣.៣ គោលបំណង

ដើម្បីកំណត់ និង ប្រៀបធៀបនូវប្រសិទ្ធិភាព និង ឥទ្ធិពលនៃវិធីទុកដាក់ផ្សេងៗទៅលើការបាត់បង់ និង គុណភាពគ្រាប់ស្រូវ ។

### ៣.៣.៤ វិធីសាស្ត្រ

*រយៈពេល* ៦ ទៅ ១២ ខែ ចាប់ពី .................. ដល់ ..................

*ចំនួនសា* ២ ឬ ៣

*បច្ច័យ* (ទៅតាមលទ្ធភាព ឬ សភាពជាក់ស្តែង)

- ក្នុងបាវធម្មតា
- ជាគំនរក្នុងជង្រុកធម្មតា
- ជាគំនរក្នុងជង្រុកបែបថ្មី
- ជាគំនរក្នុងជង្រុកដែលធ្វើអំពីបន្ទះដែក ឬ ដែកស័ង្កសី
- ក្នុងបាវធម្មតា ដាក់តម្រៀបក្នុងជង្រុកដែលមានពាស ឬ ព័ទ្ធទៅដោយសំណាញ់ដែក
- ពាង ឬ ក្រឡធ្វើពីដីឥដ្ឋ ឬ ស៊ីម៉ងត៍ ឬ បរិក្ខារដែលអាចបិទជិតបានផ្សេងទៀត ដូចដែលមានរៀបរាប់នៅក្នុងផ្នែក ២.៤.៣ ។

### ៣.៣.៥ ការស្រង់ និង វិភាគទិន្នន័យ

#### ៣.៣.៥.១ ការវាស់កំណត់ប្រចាំខែ

| ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អត្រាសំណើម. % | | | | | | | | | | | | |
| អុកស៊ីហ្សែន . % (តាមលទ្ធភាពជាក់ស្តែង) | | | | | | | | | | | | |
| អត្រាសត្វល្អិត . ក្បាល,គីឡូក្រាម | | | | | | | | | | | | |
| អត្រាដំណុះ . % | | | | | | | | | | | | |
| អត្រាអង្ករដើម. % | | | | | | | | | | | | |

### ៣.៣.៥.២ ការវាស់កំណត់នៅពេលចាប់ផ្តើម និង ពេលបញ្ចប់ (ទៅតាមលទ្ធភាព)

| ល.រ. | បច្ច័យទុកដាក់ (ជ្រើសរើសតាមសភាពជាក់ស្តែង) | អត្រាជំណេះ % | | អត្រាសត្វល្អិត *ក្បាល/គីឡូស្រូវ* | | អត្រាអង្ករដើម % | |
|---|---|---|---|---|---|---|---|
| | | ដំបូង | បញ្ចប់ | ដំបូង | បញ្ចប់ | ដំបូង | បញ្ចប់ |
| ១ | បាវធម្មតា | | | | | | |
| ២ | ជង្រុកធម្មតា | | | | | | |
| ៣ | ជង្រុកដែលបានកែលម្អ | | | | | | |
| ៤ | ជង្រុកធ្វើពីដែកស័ង្កសី | | | | | | |
| ៥ | ធុងសាំងដែលអាចបិទជិត | | | | | | |
| ៦ | បាវដាក់ក្នុងទ្រុងសំណាញ់ដែក | | | | | | |
| ៧ | កូនពាង ឬ ក្រឡដី ឬ ស៊ីម៉ងត៍ | | | | | | |
| ៨ | ធុងទឹកធ្វើពីជ័រ | | | | | | |
| ៩ | បរិក្ខារបិទជិតធំៗធ្វើពីស្បោងប្លាស្ទិក | | | | | | |
| ១០ | ថង់ស៊ុភើររបស់អ៊ីរី | | | | | | |

### ៣.៣.៥.៣ ការវាស់កំណត់អត្រាសំណើម

***សម្ភារៈបរិក្ខារដែលត្រូវការ***

- បរិក្ខារវាស់អត្រាសំណើម (រូបទី ២) និង ឯកសារណែនាំ ឬ ប្រាប់អំពីរបៀបប្រើប្រាស់
- គ្រាប់ស្រូវមួយចំនួនសមល្មមសម្រាប់ប្រើប្រាស់ជាសំណាកក្នុងការវាស់ដោយបរិក្ខារខាងលើ
- ធុង ឬ កំប៉ុងជ័រធម្មតា ឬ សាមញ្ញៗ ឬ ថង់ក្រដាស់តូចៗសម្រាប់ដាក់ ឬ ច្រកសំណាក
- ប៊ិច ឬ ខ្មៅដៃ ក្រដាស់ និង ម៉ាស៊ីនគិតលេខ សម្រាប់គណនា និង កត់ត្រាអត្រាសំណើមមធ្យមនៃសំណាក ៣ ដែលត្រូវវាស់ ។

***របៀបវាស់***

១. ចូរអានទូវការណែនាំអំពីរបៀបប្រើប្រាស់បរិក្ខារវាស់សំណើម

២. ចុចបើកបរិក្ខារនោះ

៣. ត្រូវមើលអោយប្រាកដថាបរិក្ខារនោះត្រូវបានដាក់ ឬ ចុចសម្រួលសម្រាប់ស្រូវ

៤. ដាក់សំណាកទៅក្នុងស្លាបព្រា ឬ បញ្ចូលទៅក្នុងបរិក្ខារ

៥. មួល ឬ ចុចប៊ូតុងដើម្បីអោយបរិក្ខារបង្ហាញនូវតម្លៃអត្រាសំណើម

៦. ធ្វើការវាស់អោយបានយ៉ាងតិច ៣ ដង ហើយគណនាអត្រាសំណើមមធ្យម ។

### ៣.៣.៥.៤ ការកំណត់នូវអត្រាជំណេះគ្រាប់

***សម្ភារៈបរិក្ខារដែលត្រូវការ***

- កូនថង់ធ្វើពីក្រចៅ ឬ ក្រណាត់អំបោះថ្មីៗ (រូបទី ១៨)

- គ្រាប់ស្រូវមួយចំនួនសមល្មមសម្រាប់ប្រើប្រាស់ជាសំណាក ៣
- ធុង កំប៉ុង ឬ ថាសជ័រធម្មតា ឬ សាមញ្ញៗ
- ប៊ិច ឬ ខ្មៅដៃ ក្រដាស់ និង ម៉ាស៊ីនគិតលេខ សម្រាប់គណនា និង កត់ត្រាអត្រាដំណុះ ។

***<u>របៀបវាស់</u>***

១. ដាក់តម្រៀបស្រូវ ២០០ គ្រាប់នៅលើថង់ក្រចៅ ឬ ក្រណាត់ធ្វើពីអំបោះដែលបានជ្រលក់ទឹកអោយសើមរួចហើយ

២. យកថង់ ឬ ក្រណាត់មួយទៀតដែលសើមទៅគ្របពីលើស្រូវដែលបានតម្រៀបរួចហើយនោះ

៣. ធ្វើរបៀបនេះអោយបាន ៣ (៣ រមូរ)

៤. មូរថង់ ឬ ក្រណាត់ដែលមានគ្រាប់ស្រូវនោះ ហើយទុកវានៅក្នុងម្លប់រយៈពេល ៧ ថ្ងៃ ។ ចូរផ្សើមរមូរថង់ ឬ ក្រណាត់នោះ ដោយជៀសវាងមិនធ្វើអោយវាស្ងួតក្នុងអំឡុងពេលនោះ

៥. នៅទីបំផុត ចូររាប់នូវចំនួនដើមធម្មតាដែលបានដុះ (ដើមដែលមានលក្ខណៈធម្មតា គឺជាដើមដែលមានឫស និង ដើមដងធម្មតា)

៦. គណនាអត្រាដំណុះ (គិតជាភាគរយ) ដោយប្រើរូបមន្តខាងក្រោម

$$\text{អត្រាដំណុះ} \;.\% = \frac{\text{ចំនួនដើមធម្មតា}}{\text{ចំនួនគ្រាប់ ស្រូវសរុប}} \times ១០០$$




***រូបទី ១៩ វិធីវាស់កំណត់អត្រាដំណុះ***

### ៣.៣.៥.៥ ការវាស់កំណត់អត្រាអង្ករដើម

*(កិច្ចការនេះប្រហែលជាត្រូវធ្វើដោយអ្នកដែលមានជំនាញនៅក្នុងមន្ទីរពិសោធន៍)*

***<u>សម្ភារៈបរិក្ខារ</u>***

- ម៉ាស៊ីនកិនស្រូវតូចដែលមានលក្ខណៈជាម៉ាស៊ីនមន្ទីរពិសោធន៍ ដែលនៅក្នុងម៉ាស៊ីននោះមាន ត្បាល់សម្រូប ត្បាល់សម្រិត និង បរិក្ខាររំញែកគ្រាប់អង្ករតាមប្រវែងបណ្ដោយ (រូបទី ២០)
- ជញ្ជីងតូចដែលអាចថ្លឹងបាន ៥០ ក្រាម ហើយមានបង្ហាញលេខទម្ងន់ក្នុងកម្រិត ០.១ ក្រាម
- គ្រាប់ស្រូវមួយចំនួន សមល្មមសម្រាប់ប្រើប្រាស់ជាសំណាក ៣
- ធុង កំប៉ុង ឬ ថាសជ័រធម្មតា ឬ សាមញ្ញៗ
- ប៊ិច ឬ ខ្មៅដៃ ក្រដាស់ និង ម៉ាស៊ីនគិតលេខ សម្រាប់គណនា និង កត់ត្រាអត្រាអង្ករដើម ។




***រូបទី ២០ ម៉ាស៊ីនកិនស្រូវមួយសម្រាប់ ដើម្បីវាស់កំណត់អត្រាអង្ករដើម***

***<u>របៀបវាស់</u>***

១. ហាលសម្ងួតសំណាកគ្រាប់ស្រូវអោយមានអត្រាសំណើម ១៤ %

២. សម្អាត និង ថ្លឹងសំណាកនីមួយៗ (ពី ១០០ ទៅ ១៥០ ក្រាម)

៣. ដាក់បញ្ចូលសំណាកស្រូវដើម្បីកិនសម្រូប ២ ដង ដើម្បីធ្វើអោយមាននៅសល់ស្រូវលាយឡំ ក្នុងអង្ករសម្រូបតិចតួចបំផុត និង ដើម្បីកាត់បន្ថយនូវការធ្វើអោយខូចខាតដល់ស្រទាប់កន្ទក់ (ដែលនៅជុំវិញគ្រាប់អង្ករសម្រូប) ។ មុខ ឬ ផ្ទៃរឡូកៅស៊ូទាំង ២ គួរត្រូវបានកែសម្រួល ឬ ដាក់អោយប៉ះគ្នាថើរៗ ឬ អោយឃ្លាតពីគ្នាប្រមាណជា ០,៣ មីលីម៉ែត្រ អាស្រ័យទៅតាម ទំហំគ្រាប់ស្រូវ

៤. ដាក់បញ្ចូលសំណាកអង្ករសម្រូបនោះទៅកិនក្នុងត្បាល់សម្រិតក្នុងរយៈពេលពី ២០ ទៅ ៣៥ វិនាទី ដើម្បីទទួលបានអង្ករសក្នុងកម្រិតសមល្មម (រយៈពេលកិនសម្រិតត្រូវតែដូចគ្នា សម្រាប់សំណាកទាំងអស់)

៥. ធ្វើការរំញែកអង្ករសនោះដោយប្រើប្រាស់បរិក្ខាររំញែកអង្ករតាមប្រវែងបណ្តោយ ដើម្បីញែក យកគ្រាប់អង្ករដើម និង គ្រាប់អង្ករដែលមានប្រវែងវែងជាង ៣/៤ នៃអង្ករដើម ពីចុងអង្ករ

៦. គណនាអត្រាអង្ករដើម (គិតជាភាគរយ) ដោយប្រើប្រាស់រូបមន្តខាងក្រោម ៖

$$\textit{អត្រាអង្ករដើម}\ .\% = \frac{\textit{ទម្ងន់ អង្ករដើម និង អង្ករដែលមានប្រវែងវែងជាង ៣/៤ នៃអង្ករដើម}}{\textit{ទម្ងន់ សំណាកស្រូវ}} \times ១០០$$

### ៣.៣.៥.៦ ការវាស់កំណត់អត្រាសត្វល្អិត

ការវាស់កំណត់អត្រាសត្វល្អិតមានបរិយាយនៅក្នុងផ្នែក ខ១ ។ ចំនួនសត្វល្អិតសរុប (ទាំងរស់ និង ងាប់) គួរត្រូវបានកត់ត្រាសម្រាប់ស្រូវ ១ គីឡូក្រាម ។ ក្នុងករណីពុំមានកញ្ច្រែងដែលមានបាតធ្វើពីសំណាញ់ ដែលមានរន្ធ ឬ ប្រហោងទំហំដូចដែលគេបានបញ្ជាក់ អ្នកផ្សព្វផ្សាយគួរប្រើប្រាស់សំណាញ់ការពាររុយដែលមាន រន្ធ ឬ ប្រហោងប្រហាក់ប្រហែលគ្នា ។

*ចូរពិនិត្យមើលក្នុងសំណាកស្តង់ដារ ដោយមិនសំខាន់ថាសត្វល្អិតទាំងនោះមានប្រភពមកពីណាឡើយ ។*

### ៣.៣.៦ ការអនុវត្តន៍បង្ហាញ

នៅពេលចាប់ផ្តើម ចុងបញ្ចប់ និង នៅរៀងរាល់ខែក្នុងអំឡុងពេលទុកដាក់ ភ្នាក់ងារផ្សព្វផ្សាយគួររៀបចំ អោយមានការប្រជុំជាមួយកសិករបង្គោលទាំងនោះ ព្រមទាំងគ្នីគ្នារបស់គាត់ដើម្បីរៀនសូត្រ ឬ ហ្វឹកហាត់អំពី វិធីវាស់កំណត់ ធ្វើជាសាក្សីនៃការរកឃើញថ្មី ឬ ឥទ្ធិពលខុសៗគ្នានៃវិធីទុកដាក់ដែលបានអនុវត្ត និង ដើម្បី ពិភាក្សាអំពីប្រធានបទផ្សេងៗទៀតដែលទាក់ទងនឹងបច្ចេកវិទ្យាអនុវត្តន៍ ។

### ៣.៣.៧ ការចំណាយ (ទៅតាមលទ្ធភាពជាក់ស្តែង)

| បរិយាយ | ឯកតា | បរិមាណ | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|
| កសិករ ឬ អ្នកសហការ | នាក់ ខែ | $1 \times 12$ | | |
| កម្លាំងពលកម្ម | នាក់ ថ្ងៃ | | | |
| គ្រាប់ស្រូវ | គីឡូក្រាម | | | |
| ការធ្វើដំណើរ និង ចំណាយផ្សេងៗ | | | | |
| សរុប | | | | |

### ៣.៣.៨ សកម្មភាពដែលគួរអនុវត្តនៅក្នុងអំឡុងពេលទុកដាក់

### ៣.៣.៨.១ ការពិនិត្យមើលជង្រុក ឬ កន្លែងទុកដាក់

កសិករគួរពិនិត្យមើលជង្រុក ឬ កន្លែងទុកដាក់រៀងរាល់សប្តាហ៍ ។

**<u>ការខូចខាតជង្រុក ឬ កន្លែងទុកដាក់</u>**

ការបាត់បង់គុណភាពតែងត្រូវបានកើតមានឡើងជាញឹកញាប់ដោយសារការខូចខាតជង្រុក ឬ សំណង់កន្លែងទុកដាក់ ។ គួរយកចិត្តទុកដាក់ជាពិសេសដើម្បីពិនិត្យមើលក្រែងមានដំបូលធ្លុះ ឬ ប្រហោង ចំណុចជួបរវាងដំបូល និង ជញ្ជាំង ស្នាមប្រេះ ការបាក់បែក ឬ រន្ធនៅលើជញ្ជាំង និង បាតទម្រ ការខូចខាតទ្វារ បង្អួច ច្រកអោយខ្យល់បក់ឆ្លងកាត់ និង ចម្រឹង ឬ សំណាញ់បាំងវា ។

**<u>វត្តមាននៃសត្វកណ្តុរ និង សត្វស្លាប</u>**

ត្រូវពិនិត្យមើលក្រែងមានលាមក ដានជើងនៅលើដី រន្ធធ្លុះធ្លាយនៅលើបាវ គ្រាប់ស្រូវជ្រុះកំពប់ សម្ភារះបរិក្ខារដែលខូចខាត និង សម្បកអង្កាមដែលជាសំណល់ពីការស៊ីបំផ្លាញ ។

**<u>វត្តមាននៃសត្វល្អិត</u>**

ចូរពិនិត្យរកមើលសត្វល្អិតនៅពេលព្រលឹម ឬ ព្រលប់ដោយសារថានៅពេលនោះវាតែងតែហើរចុះឡើងធ្វើ អោយងាយស្រួលក្នុងការពិនិត្យ ។

ចូរពិនិត្យមើលសំណាកស្រូវដោយរែងយកចេញនូវសត្វល្អិតដែលអាចនៅលាយឡំក្នុងស្រូវ ដោយប្រើប្រាស់កញ្ច្រែងដែលបាតសំណាញ់របស់វាមានរន្ធទំហំ ១ ទៅ ២ មីលីម៉ែត្រ ឬ យកល្អ គួរប្រើប្រាស់កញ្ច្រែងច្រើនជាន់ដែលមានរន្ធធំ តូចតាមលំដាប់ (ឧទាហរណ៍ ៣ ២ និង ១ មីលីម៉ែត្រ) ។ ត្រូវពិនិត្យអោយបានល្អិតល្អន់ដើម្បីរកមើលសត្វល្អិតដែលនៅទើរលើកញ្ច្រែងនីមួយៗ ។




*រូបទី ២១ វិធីរែងដើម្បីពិនិត្យមើលសត្វល្អិតនៅក្នុងស្រូវ*

មានសត្វល្អិតមួយចំនួនកើតមាន ហើយរស់នៅក្នុងគ្រាប់ស្រូវតែម្តង ធ្វើអោយលំបាកសង្កេតពិនិត្យ ។ ការយាយីបំផ្លាញដោយមិនបញ្ចេញអោយឃើញបែបនោះ អាចបង្ហាញអោយឃើញតាមវិធីធ្វើតេស្តដោយប្រើទឹក ចូរយកសំណាកស្រូវទៅដាក់ក្នុងផ្តិល ឬ ធុងដែលមានទឹក ។ គ្រាប់ស្រូវដែលបានទទួលរងការបំផ្លាញមានទម្ងន់ ស្រាលជាងគ្រាប់ស្រូវដែលនៅល្អ ធ្វើអោយវាអណ្តែតមកលើ ។ ចូរពិនិត្យមើលអោយបានប្រាកដថាគ្រាប់ដែលអណ្តែតទាំងនោះពិតជាបានទទួលរងការបំផ្លាញមែនដោយពុះច្រៀកបំបែកវា ។

ការយាយីបំផ្លាញខ្លាំងពីសំណាក់សត្វល្អិត អាចនឹងកំណត់ដឹងបានដោយការកើនឡើងនូវ កំដៅនៃស្រូវក្នុងជង្រុក ឬ ក្នុងបរិក្ខារទុកដាក់ ដែលជាលទ្ធផលនៃការដកដង្ហើមរបស់សត្វល្អិត ឬ ដោយសារមានក្លិនចម្លែក ។ មានពេលខ្លះ ការយាយីបំផ្លាញអាចនឹងកំណត់ដឹងបានដោយសម្លេងអ៊ូរអររបស់សត្វល្អិតនៅពេលវាស៊ីបំផ្លាញស្រូវនៅក្នុងជង្រុក ឬ កន្លែងទុកដាក់ ។

**ការដុះ ឬ ការកើតផ្សិត**

ចូរយកចិត្តទុកដាក់ទៅលើក្លិនដែលកើតមានដោយសារការដុះផ្សិត ដែលជាសញ្ញាបញ្ជាក់អំពីការយាយីបំផ្លាញ ត្បិតពេលខ្លះការពិនិត្យដោយភ្នែកទទេពុំអាចឃើញបានឡើយ ។

**ការខូចខាតដោយសារសំណើម**

ចូរយកចិត្តទុកដាក់ទៅលើស្នាមទទឹកនៅលើគំនរ ឬ បាវស្រូវ ។ ស្នាមទាំងនោះអាចនឹងមើលឃើញទោះ បីជាបាវនោះមានសភាពស្ងួតហើយក៏ដោយ ។

### ៣.៣.៨.២ ការយកសំណាក

វិធីដែលគួរអោយទុកចិត្តជាងគេដើម្បីកំណត់អំពីការខូចខាតដោយសារសំណើម សត្វល្អិត និង ការយាយីបំផ្លាញពីសំណាក់សត្វល្អិត គឺការពិនិត្យមើលស្រូវដែលបានទុកដាក់នោះផ្ទាល់ ។ ដើម្បីធ្វើកិច្ចការនេះ ចាំបាច់ត្រូវតែយកសំណាក ។ សំណាកមួយគ្រាន់តែជាផ្នែកតូចមួយនៃគ្រាប់ស្រូវទាំងអស់នៅក្នុងគំនរ ។ ហេតុនេះការយកសំណាកត្រូវតែប្រព្រឹត្តឡើងទៅតាមវិធានជាក់លាក់ និង ដោយប្រុងប្រយ័ត្នបំផុត ដើម្បីទទួលបាននូវសំណាកដែលមានលក្ខណៈតំណាងអោយគំនរ ឬ បរិមាណស្រូវទាំងមូល ។

ដើម្បីអោយមានភាពប្រាកដប្រជាបែបនោះ

- ត្រូវតែយកសំណាកបឋមអោយបានគ្រប់គ្រាន់ ឬ គ្រប់ចំនួន
- ចំណុចដែលត្រូវយកសំណាកត្រូវតែពង្រាយនៅសព្វកន្លែងក្នុងគំនរ
- ត្រូវច្របល់ចូលគ្នានូវសំណាកបឋមដើម្បីទទួលបាននូវសំណាកសមាស (លើកលែងតែសំណាកដែលត្រូវយកទៅវាស់អត្រាសំណើម)
- សំណាកសមាសត្រូវបន្ថយ ឬ បង្រួមអោយនៅតិច ឬ តូច ជាសំណាកស្តង់ដារ ដែលនឹងត្រូវធ្វើការវិភាគយ៉ាងល្អិតល្អន់ ។

សំណាកប្រភេទទាំង ៣ ដែលមាននៅក្នុងបែបបទនេះត្រូវបានកំណត់ដូចតទៅ ៖

**<u>សំណាកបឋម</u>**

សំណាកបឋមមួយ គឺជាសំណាកមួយដែលដកយកបានពីបាវមួយ ដែលសំណាកនោះមានមាឌប្រមាណជា ១០០ មីលីលីត្រ (ឬ ០.១ លីត្រ) ។ ដើម្បីទទួលបានសំណាកដែលមានលក្ខណៈតំណាងអោយគំនរទាំងមូលសំណាក បឋមដែលត្រូវយកត្រូវតែមានចំនួនច្រើនគ្រប់គ្រាន់ ។

**<u>សំណាកសមាស</u>**

សំណាកសមាសគឺជាផលនៃការច្របល់ចូលគ្នានូវសំណាកបឋម ។ វាគួរតែមានមាឌតូចបំផុតក៏ ២ លីត្រដែរ ។

**<u>សំណាកស្តង់ដារ</u>**

សំណាកស្តង់ដារមានមាឌ ១ លីត្រ គត់ ។ វាទទួលបានដោយការបន្ថយ ឬបង្រួមមាឌនៃសំណាកសមាសដោយប្រើប្រាស់បរិក្ខារញែកសំណាក (រូបទី ២២) ។ សំណាកស្តង់ដារគឺជាឯកត្តាមូលដ្ឋានសម្រាប់ការវិភាគ មើលការយាយីបំផ្លាញរបស់កត្តាចង្រៃ ។





Fig. 22. Box divider.



Fig. 23. Gamet divider.

***រូបទី ២២ បរិក្ខារញែកសំណាកមួយចំនួន***

**<u>ចំនួនសំណាកបឋម</u>**

ចំនួនសំណាកបឋមតិចបំផុត អាចប្រែប្រួលអាស្រ័យទៅតាមទំហំនៃគំនរស្រូវ ឬ បាវស្រូវ ។ ចំនួននេះអាស្រ័យជាទីបំផុតទៅនឹងចំនួនបាវស្រូវ ដោយមិនគិតថាបាវនីមួយៗធ្ងន់ ឬ ស្រាលប៉ុណ្ណាឡើយ ។

*ចំនួនសំណាកបឋមអប្បបរមាក្នុងគំនរដែលមានបាវស្រូវច្រើន*

| ចំនួនបាវ | ចំនួនសំណាក | ចំនួនបាវ | ចំនួនសំណាក | ចំនួនបាវ | ចំនួនសំណាក |
|---|---|---|---|---|---|
| តិចជាង 10 | 1 ពីបាវនីមួយៗ | 800 - 900 | 30 | 2500 - 3000 | 55 |
| 50 - 100 | 10 | 900 - 1000 | 32 | 3000 - 3500 | 59 |
| 100 - 150 | 12 | | | 3500 - 4000 | 63 |
| 150 - 200 | 14 | 1000 - 1200 | 35 | 4000 - 4500 | 67 |
| 200 - 250 | 16 | 1200 - 1400 | 37 | 4500 - 5000 | 71 |
| 250 - 300 | 18 | 1400 - 1600 | 40 | 5000 - 6000 | 77 |
| 300 - 400 | 20 | 1600 - 1800 | 42 | 6000 - 7000 | 83 |
| 400 - 500 | 22 | 1800 - 2000 | 45 | 7000 - 8000 | 89 |
| 500 - 600 | 24 | | | 8000 - 9000 | 95 |
| 600 - 700 | 26 | 2000 - 2500 | 50 | 9000 - 10000 | 100 |
| 700 - 800 | 28 | | | | |

នៅពេលប្រគល់ទទួលស្រូវ គួរយកសំណាកបឋម ១ ក្នុងចំណោមបាវ ២ នៅលើយានយន្ត ។

**ចំណុចដែលត្រូវយកសំណាក**

ចំណុចដែលត្រូវយកសំណាកត្រូវតែនៅរាយប៉ាយសព្វកន្លែងលើផ្ទៃសរុបរបស់គំនរមានន័យថា សម្រាប់ផ្ទៃដែល ធំ ចំណុចដែលត្រូវយកសំណាកត្រូវតែច្រើនទៅតាមនោះដែរ ។ ប្រសិនបើផ្ទៃសរុបនោះមានទំហំ ១២០ ម៉ែត្រ ការ៉េ (ជាឧទាហរណ៍) ហើយផ្ទៃម្ខាងៗមានទំហំ ៤០ ម៉ែត្រការ៉េ ត្រូវតែយក ១ ភាគ ៣ នៃសំណាក ពីផ្នែកម្ខាងនោះ ។ នៅខាងផ្នែកដែលមានផ្ទៃ ២៤ ម៉ែត្រការ៉េ ត្រូវតែយក ១ ភាគ ៥ នៃសំណាក ទៅតាមនោះ ។




*រូបទី ២៣ ទីតាំងនៃចំណុចដែលត្រូវយកសំណាក*

### ៣.៣.៨.៣ ការពិនិត្យគុណភាព

យ៉ាងហោចណាស់ គួរតែមានសម្ភារៈបរិក្ខារមួយចំនួន ដូចមានរៀបរាប់ខាងក្រោមដើម្បីប្រើប្រាស់ក្នុងការពិនិត្យគុណភាពគ្រាប់ស្រូវ

- បរិក្ខារវាស់សំណើម
- កញ្ច្រែងមួយចំនួន
- កែវពង្រីកកាន់ដោយដៃ និង
- ជញ្ជីងមួយ ។

**ការវាស់កំណត់អត្រាសំណើម**

ការវាស់កំណត់នេះគួរតែត្រូវអនុវត្តភ្លាមៗបន្ទាប់ពីការយកសំណាក ដោយសារថាអត្រាសំណើមអាចប្រែប្រួលយ៉ាងលឿន ។ ជាទូទៅ កិច្ចការនេះតែងត្រូវបានគេអនុវត្តដោយប្រើប្រាស់បរិក្ខារវាស់សំណើម ។

ក្នុងករណីដែលពុំអាចរកបរិក្ខារនេះបាន អ្នកដែលមានបទពិសោធន៍អាចប្រមាណដឹងខ្លះអំពីភាពសមស្រប របស់ ស្រូវសម្រាប់ការទុកដាក់តាមវិធីពិនិត្យដោយភ្នែក ស្ទាប និង ភាពរឹងរបស់គ្រាប់ស្រូវនីមួយៗ ។

**ការវាស់កំណត់សីតុណ្ហភាពគ្រាប់ស្រូវ**

សីតុណ្ហភាព ឬ កំដៅគ្រាប់ស្រូវអាចនឹងត្រូវវាស់កំណត់បានដោយប្រើប្រាស់ទែម៉ូម៉ែត្រ ។ ទែម៉ូម៉ែត្រសម្រាប់ស្រូវត្រូវបានគេផលិតអោយមានដងស្ទង់ធ្វើពីលោហៈរឹងដែលអាចស៊កទំលុះសម្បកបាវបាន ។ ទែម៉ូម៉ែត្រអេឡិចត្រូនិក ច្រើនមានបរិក្ខារស្ទង់ធ្វើអំពីសំណដែលអាចបត់បែនបាន ។ សំណនោះអាចត្រូវបានគេផ្សារភ្ជាប់ជាមួយសរសៃលោហៈរឹង ឬមួយដាក់បញ្ចូលទៅក្នុងបាវ ឬ ទៅក្នុងដែកឆាំ ។

តាមធម្មតា កំដៅខ្ពស់នៅក្នុងគំនរស្រូវគឺជាសញ្ញាដែលបញ្ជាក់ថាមានសកម្មភាពបំផ្លាញរបស់សត្វល្អិត ជាឧទា ហរណ៍ គឺនៅក្នុង "ចំណុចក្តៅ" ។ ភ្នាក់ងារផ្សព្វផ្សាយហើយនិងកសិករគួរតែចាក់ស្រូវចេញពីបាវដែលក្តៅ នោះអោយអស់ ដើម្បីពិនិត្យ ព្រមទាំងកំណត់អំពីទំហំ ឬ កម្រិតនៃការបំផ្លាញ ឬ ការខូចខាតចំពោះស្រូវក្នុងបាវទាំងឡាយដែលនៅក្បែរខាង ។

### ៣.៣.៨.៤ ការវាយតម្លៃអំពីការបាត់បង់

វិធីដែលសាមញ្ញបំផុតក្នុងការកំណត់អំពីការបាត់បង់បរិមាណនៅក្នុងពេលទុកដាក់គឺការកត់ត្រានូវបរិមាណស្រូវចូល និង ចេញ (វិធីថ្លឹងចូល ថ្លឹងចេញ) ។ ផ្សេងពីនេះទៅវិញ ដោយសារតែមូលហេតុទាំងឡាយខាងក្រោមច្រើនធ្វើអោយមានភាពស្មុគស្មាញក្នុងការកំណត់អំពីការបាត់បង់បរិមាណ

- ពុំមានវិធីគណនាអំពីការបាត់បង់ណាដែលមានភាពសាមញ្ញ រហ័ស គួរអោយទុកចិត្ត និង អាចអនុវត្តកើតក្នុងពេលព្រមៗគ្នាឡើយ
- ជាញឹកញាប់ គេពុំអាចដឹងអោយបានជាក់លាក់នូវបរិមាណគ្រាប់ស្រូវដែលប្រមូលបាន ជាពិសេសសម្រាប់ការទុកដាក់តាមកសិដ្ឋានតូចតាច (ឧទាហរណ៍ ក្នុងគ្រួសារកសិករ) ធ្វើអោយគេគ្រាន់តែអាចដឹងថាមានការបាត់បង់នៅពេលក្រោយមក ប៉ុន្តែមិនដឹងអំពីបរិមាណពិតប្រាកដ
- ក្នុងករណីដែលមានការយាយីបំផ្លាញពីសំណាក់សត្វល្អិត ការស្រកចុះទម្ងន់មិនអាស្រ័យទៅនឹងភាពខុសគ្នានៃទម្ងន់នៅមុន និង ក្រោយពេលបំផ្លាញឡើយ ។ នៅពេលយកផលិតផលទៅថ្លឹង កាកសំណល់ កំទិចស្មៅ សំណាញ់ (ពីងពាង) សត្វល្អិតដែលងាប់ហើយ និង លាមកកណ្តុរដែលនៅលាយឡំក៏តែងត្រូវបានសរុបចូលដែរ ។ ដោយសន្មត់ថាសារធាតុលាយឡំទាំងអស់នេះពុំអាចបំបែកយកចេញពីផលិតផលបាន ការបាត់បង់ជាបរិមាណជាក់ស្តែងមានទំហំខ្ពស់ជាងអ្វីដែលបានគណនា ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ២០០ វិថីព្រះនរោត្តម ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧
ទូរសារ ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១
អ៊ីម៉ែល kunso@camnet.com.kh ឬ mak_soeun@camnet.com.kh